ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា

# របាយការណ៍
# លទ្ធផលមហាសន្និបាតបូកសរុបការងារអប់រំឥស្លាម ឆ្នាំ ២០១៥-២០២៣ និងទិសដៅការងារបន្ត

## ក្រោមប្រធានបទ
## «កំណែទម្រង់វិស័យអប់រំឥស្លាមក្នុងបរិបទឌីជីថល»

ថ្ងៃទី ៥-៦ ខែមីនា ឆ្នាំ២០២៤

# មាតិកា

មាតិកា....................2
១. សេចក្តីផ្តើម....................3
១.១ សមាសភាពចូលរួម....................3
១.២ គោលបំណង....................3
១.៣ កម្មវិធីអម....................3
១.៤ ដំណើរការមហាសន្និបាត....................3
២. វឌ្ឍនភាពវិស័យអប់រំឥស្លាមរយៈពេល ៨ឆ្នាំ (២០១៥-២០២៣)....................4
២.១ ស្ថិតិគ្រូបង្រៀនខ្មែរឥស្លាម....................4
២.២ ស្ថិតិសិស្សខ្មែរឥស្លាម....................4
២.៣ ស្ថិតិថ្នាក់រៀន អគារសិក្សាសាលារៀនសហគមន៍ និងសាលារៀនឯកជន....................4
២.៤ រចនាសម្ព័ន្ធគ្រប់គ្រង....................5
២. ៥.កម្មវិធីសិក្សាអប់រំឥស្លាម....................5
២.៦ ការប្រឡង....................6
២.៧ បច្ចុប្បន្នភាពសិស្ស-និស្សិតកំពុងសិក្សាក្រៅប្រទេស....................7
២.៨ ការចូលរួមរបស់សហគម....................7
៣. ទស្សនវិស័យសម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥ និងទសដៅបន្ត....................7
៤. វិស័យអប់រំឥស្លាមឆ្លើយតបទៅនឹងបញ្ហាប្រឈម....................9
៥. សេចក្តីសន្និដ្ឋាន....................11
ឧបសម្ព័ន្ធទី១ ឯកសារទស្សនាទាន....................12
ឧបសម្ព័ន្ធទី២ សុន្ទរកថាបើក និងបិទ....................4
ឧបសម្ព័ន្ធទី៣ កម្រងរូបភាពសកម្មភាពក្នុងមហាសន្និបាត....................13
ឧបសម្ព័ន្ធទី៤ បញ្ជីវត្តមានអ្នកចូលរួមមហាសន្និបាតអប់រំឥស្លាម....................24

## ១. សេចក្តីផ្តើម

ដើម្បីបូកសរុបការងារ និងពិនិត្យអំពីវឌ្ឍនភាព ស្ថានភាពវិស័យអប់រំកាយនៅកម្ពុជា រយៈពេលកន្លងមក ក្រោយការដាក់បញ្ចូលគ្រូបង្រៀនខ្មែរកាយជាមន្ត្រីរាជការស៊ីវិលនៃក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងឆ្លុះបញ្ចាំង បញ្ហាប្រឈម និងដំណោះស្រាយ និងលើកទិសដៅការងារដើម្បីអភិវឌ្ឍវិស័យអប់រំកាយកម្ពុជា គណៈដឹកនាំជាន់ខ្ពស់នៃសាសនាកាយកម្ពុជា សហការជាមួយសមាគមគ្រូបង្រៀនខ្មែរកាយ បានរៀបចំមហាសន្និបាតបូកសរុបការងារវិស័យអប់រំកាយ ឆ្នាំ២០១៥-២០២៣ និងលើកទិសដៅបន្ត ក្រោមប្រធានបទ៖ «កំណែទម្រង់វិស័យអប់រំកាយក្នុងបរិបទឌីជីថល» ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី៥ ដល់ទី៦ ខែមីនា ឆ្នាំ២០២៤ នៅវិទ្យាស្ថានជាតិអប់រំ។

### ១.១ សមាសភាពចូលរួម

សមាសភាពអ្នកចូលរួមមហាសន្និបាត មកពីវិស័យអប់រំគ្រប់លំដាប់ថ្នាក់ ថ្នាក់ដឹកនាំកាយតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងតាមបណ្តារាជធានីខេត្តទូទាំងប្រទេស និងតំណាងអង្គការសមាគមពាក់ព័ន្ធនានា ដោយអ្នកចូលរួមផ្ទាល់ក្នុងអង្គមហាសន្និបាតមានប្រមាណ ៥៩៣នាក់ ក្នុងនោះភ្ញៀវកិត្តិយសប្រមាណ១០០នាក់ និងមានអ្នកចូលរួមតាមប្រព័ន្ធអនឡាញប្រមាណ១,០០០នាក់ ។

### ១.២ គោលបំណង

មហាសន្និបាតប្រារព្ធឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ពិនិត្យវឌ្ឍនភាពសមិទ្ធផលការងារ បញ្ហាប្រឈម ដំណោះស្រាយ និងលើកទិសដៅការងារបន្ត
- វេទិកាពិភាក្សាលើស្ថានភាពអប់រំកាយ ទិសដៅ និងការរៀបចំអនុវត្តគោលនយោបាយអប់រំកាយ
- ទទួលបានធាតុចូលសំខាន់ៗ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

### ១.៣ កម្មវិធីរួម

ដើម្បីបង្ហាញអំពីសមទ្ធផលនានា ដែលអនុវត្តបានកន្លងមក និងដើម្បីញុំាងឱ្យដំណើរប្រព្រឹត្តទៅនៃមហាសន្និបាតកាន់តែរលូន គណៈកម្មការរៀបចំមហាសន្និបាតនឹងរៀបចំកម្មវិធីរួមសំខាន់ៗមួយចំនួនដូតទៅ៖

១. ការតាំងពិព័រណ៍ដាក់បង្ហាញអំពីសមទ្ធផលអប់រំ របស់គ្រឹះស្ថានសិក្សាសហគមន៍ និងអង្គការសមាគមមួយចំនួន ដើម្បីបង្ហាញជូនថ្នាក់ដឹកនាំ និងអង្គមហាសន្និបាតទស្សនាឈ្វេងយល់។

២. ការប្រឡងជ្រើសរើស ផ្តល់រង្វាន់ស្នាដៃតែងនិពន្ធខុទ្ទពះ ជ័យលាភីទូទាំងប្រទេស ដើម្បីរួមចំណែកលើកស្ទួយវិស័យអប់រំកាយនៅកម្ពុជា ។

### ១.៤ ដំណើរការមហាសន្និបាត

មហាសន្និបាតបូកសរុបការងារអប់រំកាយ ឆ្នាំ២០១៥-២០២៣ និងទិសដៅការងារបន្ត ក្រោមប្រធានបទ៖ **«កំណែទម្រង់វិស័យអប់រំកាយក្នុងបរិបទឌីជីថល»** បានប្រព្រឹត្តទៅរយៈពេល ០២ថ្ងៃ ចាប់ពីថ្ងៃទី៥ ដល់ទី៦ ខែមីនា ឆ្នាំ២០២៤ នៅវិទ្យាស្ថានជាតិអប់រំ។ ពិធីបើកមហាសន្និបាតស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត អ៊ូស្វាន ហាស្សាន់ ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស** និងពិធីបិទមហាសន្និបាតស្ថិតក្រោមអធិបតីភាព

**ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។** កិច្ចពិភាក្សាពេញអង្គនឹងប្រព្រឹត្តទៅដោយមានវេទិកាពិភាក្សាចំនួនពីរ និងមានបទបង្ហាញពាក់ព័ន្ធប្រធានសំខាន់មួយចំនួនដោយមានការចូលរួមពីវាគ្មិនជំនាញជាតិ និងអន្តរជាតិ ។

## ២. ចន្លោះភាពវិស័យអប់រំឥស្លាមរយៈពេល ៨ឆ្នាំ (២០១៥-២០២៣)

### ២.១ ស្ថិតិគ្រូបង្រៀនខ្មែរឥស្លាម

នៅឆ្នាំ២០១៥ សហគមន៍ឥស្លាមទទួលបានគ្រូបង្រៀនក្របខណ្ឌនៃក្រសួងអប់រំ យុវជន និងកីឡា ចំនួន ១ ៣៩១ នាក់ ស្រី ៣ ៣៣៤ នាក់ ក្នុងនោះក្របខណ្ឌ "ក" ១៧៧នាក់ ស្រី ៣៦នាក់ ក្របខណ្ឌ "ខ" ៨៣៩នាក់ស្រី ១៨០នាក ក្របខណ្ឌ "គ" ៣៧៥នាក់ស្រី ១២១នាក់ គ្រូបង្រៀនក្របខណ្ឌក្រុមកនអ៊ីមុំាសាន់ (ឧកញ៉ាឃ្នួរ) ចំនួន ៣៩នាក់ ស្រី ០៣នាក់។ គ្រូបង្រៀនជាប់កិច្ចសន្យាចំនួន ១៧៨នាក់ ស្រី ៤៤នាក់។

គិតត្រឹមឆ្នាំ២០២៣ គ្រូបង្រៀនខ្មែរឥស្លាមក្របខណ្ឌ និងឯកជនសរុបចំនួន ៣ ៩១៨នាក់ ស្រី ១ ១៨២នាក់ ក្នុងនោះគ្រូបង្រៀនក្របខណ្ឌចំនួន ១២៦៣នាក់ ស្រី៣១៩នាក់គ្រូបង្រៀនក្របខណ្ឌក្រុមកនអ៊ីមុំាសាន់ ចំនួន ៨៦នាក់ ស្រី ១១នាក់ និងគ្រូបង្រៀនស្ម័គ្រចិត្ត សាលារៀនសហគមន៍ចំនួន ៩៥៣នាក់ ស្រី ២៨៦នាក់។ គ្រូបង្រៀនជាប់កិច្ចសន្យាចំនួន ១៧៣ នាក់ ស្រី៥២នាក់។ គិតចាប់ពីឆ្នាំ២០១៥ រហូតដល់ ឆ្នាំ២០២៣ គ្រូបង្រៀនខ្មែរឥស្លាមក្របខណ្ឌមានការថយចុះចំនួន១២៨នាក់ និងគ្រូបង្រៀនជាប់កិច្ចសន្យា មានការថយចុះចំនួន ០៥នាក់។ ចំនួនគ្រូបង្រៀនខ្មែរឥស្លាមក្របខណ្ឌ មានការថយចុះដោយសារកត្តាមួយចំនួនដូចជា ដល់អាយុចូលនិវត្តន៍ មរណភាព ការផ្ទេរនៅក្រៅក្របខណ្ឌដើម និងការលាលែងពីក្របខណ្ឌ។ ដោយឡែកគ្រូបង្រៀនខ្មែរឥស្លាមសាលារៀនឯកជន មានចំនួន ១ ៤៤៣នាក់ ស្រី ៥១៤នាក់ ក្រោមការទំនុកបម្រុងរបស់សមាគម អង្គការ ឬវិស័យឯកជនភាគច្រើនទទួលជំនួយពីសប្បុរសជននៅក្រៅប្រទេស។

### ២.២ ស្ថិតិសិស្សខ្មែរឥស្លាម

ក្នុងឆ្នាំសិក្សា ២០២២-២០២៣ អាត្រានៃការចូលរៀនរបស់សិស្សខ្មែរឥស្លាមសាលារៀនសហគមន៍ និងសាលារៀនឯកជនសរុប ៧១ ០១០នាក់ ស្រី ៣៨ ៤២០នាក់ ក្នុងនោះមត្តេយ្យសិក្សាចំនួន ៨ ២២៧ នាក់ ស្រី ៤ ០២៥នាក់ បឋមសិក្សាចំនួន ៥៣ ៩៣៧នាក់ ស្រី ២៩ ៩០៥នាក់ មធ្យមសិក្សាបឋមភូមិចំនួន ៦ ៦៥១នាក់ ស្រី ៣ ៣៧៤នាក់ និងមធ្យមសិក្សាទុតិយភូមិចំនួន ២ ១៩៥នាក់ ស្រី ១ ១១៦នាក់។

### ២.៣ ស្ថិតិថ្នាក់រៀន អគារសិក្សាសាលារៀនសហគមន៍ និងសាលារៀនឯកជន

**ក. ថ្នាក់រៀន**

ក្នុងឆ្នាំ២០២៣ មានចំនួន ៣៥២៨ថ្នាក់ ដែលមានតាមកម្រិតថ្នាក់មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមសិក្សា និងមធ្យមសិក្សាទុតិយភូមិ ។

**ខ.អគារសិក្សា**

នៅក្នុងឆ្នាំ២០២៣ ចំនួនអគារសិក្សាសាលារៀនសហគមន៍ និងសាលារៀនឯកជន សរុបចំនួន ១៦៥៧ខ្នង ស្មើនឹង ៤៩២០បន្ទប់ ក្នុងនោះអគារសិក្សាជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** មានចំនួន ២២ខ្នង ស្មើនឹង ២៤៤បន្ទប់។

## ២.៤ រចនាសម្ព័ន្ធគ្រប់គ្រង

គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជាបានរៀបចំ គណៈកម្មការសម្របសម្រួលការអប់រំឥស្លាម នៅថ្នាក់កណ្តាល និងក្រុមការងារគ្រូបង្រៀនខ្មែរឥស្លាម នៅថ្នាក់រាជធានី ខេត្ត រហូតដល់មូលដ្ឋាន សម្រាប់សម្របសម្រួលការងាររដ្ឋបាលអប់រំ ដោយត្រូវបានចាត់តែងជាគ្រប់គ្រងរដ្ឋបាល ឬនាយករាជធានី ខេត្ត នាយកក្រុង ស្រុក ខណ្ឌ នាយកកម្រង និងនាយកសាលារៀន ក្រោមការដឹកនាំ និងគ្រប់គ្រងពីគណៈអ៊ីម៉ាំរាជធានីខេត្ត អ៊ីម៉ាំក្រុង ស្រុក ខណ្ឌ និងអ៊ីម៉ាំម៉ាស្ជិទ។ ក្រុមការងារនេះបាន និងកំពុងបំពេញភារកិច្ចជាសេនាធិការជូនថ្នាក់ដឹកនាំឥស្លាម ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធ ។ ជាមួយគ្នាគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជាបានរៀបចំបង្កើតជាគណៈកម្មការសម្របសម្រួលការអប់រំឥស្លាមនៅថ្នាក់កណ្តាល ក្នុងការសម្របសម្រួលជាមួយមន្រ្តីគ្រប់គ្រងរដ្ឋបាលអប់រំឥស្លាម ថ្នាក់រាជធានីខេត្ត។ ដោយឡែកនៅតាមសាលារៀនសហគមន៍ខ្មែរឥស្លាម គណៈគ្រប់គ្រងសាលារៀនពុំទាន់មានការទទួលស្គាល់ផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។ ចំពោះការងាររៀបចំគោលនយោបាយនៅឆ្នាំ២០១៩ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគណៈកម្មការអភិវឌ្ឍគោលនយោបាយស្តីពី «**ការអប់រំឥស្លាម និងផែនការសកម្មភាព**» ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងមានសមាសភាពពីឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ ជាគណៈកម្មការដឹកនាំ និងប្រធានអង្គភាពជំនាញនៃក្រសួងអប់រំ យុវជន និងកីឡាមួយចំនួន និងសមាសភាពពីគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ជាគណៈកម្មការបច្ចេកទេស និងលេខាធិការដ្ឋាន។

## ២. ៥.កម្មវិធីសិក្សាអប់រំឥស្លាម

ប្រព័ន្ធអប់រំឥស្លាមនៅកម្ពុជាមាន៤កម្រិតភូមិសិក្សា ដូចជា មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិឥស្លាម និងមធ្យមសិក្សាទុតិយភូមិឥស្លាម។ ចំពោះកម្មវិធីសិក្សាសាលារៀនសហគមន៍បានអនុវត្តតាមការណែនាំពីគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា។ កម្មវិធីសិក្សនៅកម្រិតមត្តេយ្យ គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា បានសហការជាមួយនាយកដ្ឋានសាសនាឥស្លាមរដ្ឋសហព័ន្ធកូឡាឡាំពួរ (JAWI) តាមរយៈ នាយកដ្ឋានអភិវឌ្ឍន៍ឥស្លាមម៉ាឡេស៊ី (JAKIM) ប្រទេសម៉ាឡេស៊ី ដែលមានមុខវិជ្ជា មានមុខវិជ្ជា៖ គម្ពីរអាល់គួរអានុលការីម ភាសាអារ៉ាប់ ហាហ្វីស (ទន្ទេញចាំមាត់គម្ពីរអាល់គួរអាន) ទូអា (ធម៌បួងសួង) ភាសាបរទេស (អង់គ្លេស) គណិតវិទ្យា និងភាសាខ្មែរ។

សម្រាប់កម្មវិធីសិក្សាកម្រិតបឋមសិក្សា គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា បានអនុវត្តតាមកម្មវិធីសិក្សារបស់ប្រទេសម៉ាឡេស៊ី (JAIS ) ដែលមានមានមុខវិជ្ជា៖ គម្ពីរអាល់គួរអានុលការីម និងហាហ្វីស តៅហេត (គោលជំនឿឥស្លាម) ហ្វីកោះ (ធម៌វិន័យឥស្លាម) អើខឡើក (សីលធម៌) អ៊ីមឡាក (ភាសាគោល) ស៊ីរោះ (ប្រវត្តិវិទ្យា) ត័ជ្វិទ (ក្បួនខ្នាតសូត្រគម្ពីរអាល់គួរអាន) ភាសាអារ៉ាប់ និងភាសាបរទេស (អង់គ្លេស)។

ចំពោះកម្មវិធីសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិឥស្លាម (SMU) ត្រូវបានគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជាយកតាមប្រព័ន្ធអប់រំរបស់ប្រទេសម៉ាឡេស៊ី (Yayasan Islam Kelantan) ដែលមានមានមុខវិជ្ជាៈ គម្ពីរអាល់គួរអានុលការីម និងហាហ្វីស តាហ្វសៀរ (បកស្រាយអត្ថន័យគម្ពីរអាល់គួរអាន) ហ្វីកោះ អើខឡើក អ៊ីមឡាក ស៊ីរោះ ត៍ផ្ទិទ ភាសាអារ៉ាប់ ភាសាបរទេស (អង់គ្លេស) តៅហេត អាល់ហាទីស (មាគ៌ាព្យាការីមូហាំម៉ាត់) ណាហ៊ូ និងសារ៉ហ្វ (វេយ្យាករណ៍ភាសាអារ៉ាប់) និងមូតាឡាអះ (អក្សរសិល្ប៍)។

ចំណែកកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមឥស្លាម (STAM) វិញ ត្រូវបានយកតាមប្រព័ន្ធអប់រំរបស់ក្រសួងអប់រំម៉ាឡេស៊ី ដែលមានមានមុខវិជ្ជាៈ គម្ពីរអាល់គួរអានុលការីម និងហាហ្វីស តាហ្វសៀរ អ៊ុលូមគួរអាន (បកស្រាយអត្ថន័យគម្ពីរអាល់គួរអាន) ត៍ផ្ទិទ ភាសាអារ៉ាប់ ភាសាបរទេស (អង់គ្លេស) តៅហេត ហ្វីកោះ ហាទីស អ៊ុលូមហាទីស (វិជ្ជាបកស្រាយប្រសាសន៍ព្យាការី) ណាហ៊ូ និងសារ៉ហ្វ មូតាឡាអះ អិនហ្សាក (តែងសេចក្ដី) អាល់ពើឡាហ្គោះ (វោហាសាស្ត្រ) អាដាប និងនូស៊ូស (អក្សរសាស្ត្រអារ៉ាប់) ម៉ាន់តិក (តក្កវិទ្យា) អាល់ហ្វារ៉អ៊ីទ (ក្បួនចែកមរតក) អាល់អារូទ និងកហ្វីយ៉ះ (កំណាព្យភាសាអារ៉ាប់)។

ដោយឡែកសាលារៀនក្រុមកនអ៊ីម៉ាំសាន់ (ឧកញ៉ាឃ្នួរ) ប្រើប្រាស់កម្មវិធីសិក្សាផ្សេងទៀត មានលក្ខណៈប្រពៃណីយ៍ និងបង្រៀនអំពីអក្សរចាម្ប៉ា។ ចំពោះសាលារៀនឯកជន និងមជ្ឈមណ្ឌលរបស់អង្គការ សមាគមកម្មវិធីសិក្សាអនុវត្តតាមការជ្រើសរើសរបស់គណៈគ្រប់គ្រង ឬនាយកសាលាដែលភាគច្រើនបានបញ្ចប់ការសិក្សាពីក្រៅប្រទេសដោយមិនអនុវត្តតាមកម្មវិធីសិក្សារៀបចំដោយគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជានោះទេ ។

## ២.៦ ការប្រឡង

ការប្រឡងសញ្ញាបត្របឋមសិក្សាឥស្លាមស្តង់ដាទូទាំងប្រទេសត្រូវបានរៀបចំប្រឡើងចាប់ពីឆ្នាំ២០២១៩ ចំណែកការប្រឡង មធ្យមសិក្សាបឋមភូមិឥស្លាមស្តង់ដា (SMU)ត្រូវបានរៀបចំប្រឡងចាប់ពីឆ្នាំ២០០២។ ចំពោះការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឥស្លាមស្តង់ដា ថ្នាក់ជាតិ ត្រូវបានរៀបចំឡើងជាលើកដំបូងនៅឆ្នាំសិក្សា ២០១៥-២០១៦ និងអនុវត្តបន្តបន្ទាប់រហូតមកដល់ឆ្នាំសិក្សា ២០១៩-២០២០ ក្រោមកិច្ចសហការជាមួយក្រសួងអប់រំនៃប្រទេសម៉ាឡេស៊ី ដោយបើកមជ្ឈមណ្ឌលប្រឡងសញ្ញាបត្រជាន់ខ្ពស់ម៉ាឡេស៊ីផ្នែកសិក្សាសាសនាឥស្លាម ហៅកាត់ថា STAM នៅកម្ពុជា។ ដោយឡែក ចាប់ពីឆ្នាំសិក្សា ២០២០-២០២១ គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាម ម្ចាស់ការរៀបចំប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឥស្លាមស្តង់ដា នៅកម្ពុជា ហៅកាត់ថា STAK បានបន្តរៀបចំការរហូតមកដល់បច្ចុប្បន្ន ហើយបានប្រគល់សញ្ញាបត្រជូនសិស្សជ័យលាភីទាំងអស់ដែលមានការទទួលស្គាល់ពីបណ្តាសាកលវិទ្យាល័យនានានៅប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងបណ្តាប្រទេសអារ៉ាប់ជាច្រើនទៀត។

គិតចាប់ពីឆ្នាំ២០២១ ដល់ ឆ្នាំ២០២៣សិស្សខ្មែរឥស្លាមដែលកំពុងសិក្សាតាមគ្រឹះស្ថានអប់រំរដ្ឋ និងឯកជនបានចូលរួមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះដឹងទូទៅ សរុបចំនួន ២ ៧៣៦នាក់ ស្រី ១ ៥៦៤នាក់ ។ អត្រានៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សាទុតិយភូមិចំណេះទូទៅរបស់សិស្សខ្មែរឥស្លាមមានការកើនឡើង ហើយអត្រានៃការបោះបង់ការសិក្សាក៏បានកាត់បន្ថយ ខណៈដែលការចុះឈ្មោះចូលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក៏បានកើនឡើង គឺ ១៥ភាគរយ នៅឆ្នាំ២០២២ និង ៣៩ភាគរយ នៅឆ្នាំ២០២៣។

### ២.៧ បច្ចុប្បន្នភាពសិស្ស-និស្សិតកំពុងសិក្សាក្រៅប្រទេស

នៅក្នុងឆ្នាំសិក្សា ២០២៣-២០២៤ ចំនួនសិស្ស-និស្សិតសរុបមានចំនួន ១ ០៩៦នាក់ ស្រី១៧៧នាក់ កំពុងសិក្សានៅប្រទេសចំនួន ១២ ក្នុងនោះរួមមានប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ តួកគី អារ៉ាប៊ីសាអូឌីត អារ៉ាប់រួមអេមីរ៉ាត អេស៊ីបលីប៊ី ហ្សកដានី ប៉ាគីស្ថាន ស៊ូដង់ និងគុយវ៉ែត ក្នុងនោះ ថ្នាក់បណ្ឌិតមានចំនួន ៣នាក់ ថ្នាក់អនុបណ្ឌិតមានចំនួន ២៦នាក់ ថ្នាក់បរិញ្ញាបត្រមានចំនួន ៦០៤នាក់ ថ្នាក់វិទ្យាល័យមានចំនួន ៣២នាក់ ផ្នែកសាសនាមានចំនួន ២៨៦នាក់។

### ២.៨ ការចូលរួមរបស់សហគមន៍

គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជាបាន ធ្វើការណែនាំដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា រៀបចំឱ្យមានយន្តការគ្រប់គ្រងសមស្រប ក្នុងការទទួលបានការចូលរួមគាំទ្រពីសហគមន៍មូលដ្ឋានរបស់គ្រឹះស្ថានសិក្សា និងរៀបចំបង្កើតគណៈកម្មការទ្រទ្រង់គ្រឹះស្ថាន ដើម្បីធានាបានដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

## ៣. បញ្ហាប្រឈម និងសំណូមពរ

ទន្ទឹមនឹងសមិទ្ធផលជាច្រើនដែលសម្រេចបានក្នុងរយៈពេលកន្លងមក មានកិច្ចការជាច្រើនទៀតដែលត្រូវបន្តជំរុញអនុវត្ត និងសម្រេចឱ្យបានលទ្ធផលថ្មីៗបន្ថែមទៀត ស្របតាមគោលនយោបាយកំណែទម្រង់វិស័យអប់រំរបស់រាជរដ្ឋាភិបាល ដូចដែលខ្ញុំបាទទើបបានលើកឡើងមុននេះ។ ជាមួយគ្នានេះ ការអភិវឌ្ឍវិស័យអប់រំឥស្លាម ក៏ជួបបញ្ហាប្រឈមមួយចំនួនផងដែរ។ បន្ទាប់ពីដំណើការសន្និបាត រយៈពេលពីរថ្ងៃនេះ អង្គសន្និបាតបានប្រមូលជាតុចូលសំខាន់ៗ និងសំណូមពរ ដូចខាងក្រោម៖

### ៣.១ បញ្ហាប្រឈម

- រចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងយន្តការអភិវឌ្ឍ មិនទាន់មានការទទួលស្គាល់ផ្លូវការ
- កម្មវិធីសិក្សាឥស្លាមតាមកម្រិតភូមិសិក្សា ពុំទាន់មានការទទួលស្គាល់ជាផ្លូវការពីក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រឹះស្ថានសិក្សាឥស្លាម ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា ដំណើរការក្រោមរូបភាពសាលាសហគមន៍មួយចំនួនធំ ពុំទាន់មានអាជ្ញាបណ្ណទទួលស្គាល់ជាផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា នៅឡើយ ។
- ការបណ្តុះបណ្តាល និងវិក្រឹត្តការគ្រូ៖ ពុំទាន់មានគ្រឹស្ថានបណ្តុះបណ្តាលគរុកោសល្យ និងវិក្រឹត្តការសម្រាប់គ្រូ និងបុគ្គលិកឥស្លាម នៅឡើយ
- ប្រភពធនធានគាំទ្រ៖ សាលារៀនឥស្លាមសហគមន៍ និងឯកជន ពុំទាន់មានធនធានរឹងមាំ សម្រាប់ដំណើរការ និងខ្វះសម្ភារៈរូបវន្ត សម្រាប់ការអភិវឌ្ឍសាលារៀន និងធានានិរន្តរភាព
- ប្រព័ន្ធអធិការកិច្ច៖ មិនទាន់បានរៀបចំនៅឡើយ ការបណ្តុះបណ្តាលមន្ត្រីអធិការកិច្ច និងយន្តការចុះពិនិត្យតាមដាន និងវាយតម្លៃជាដើម ។

### ៣.២. សំណូមពរ

ស្នើរៀបចំអភិវឌ្ឍគោលនយោបាយស្តីពីការអប់រំឥស្លាម និងក្របខណ្ឌកម្មវិធីសិក្សា ដើម្បីជាត្រីវិស័យ សម្រាប់ការអភិវឌ្ឍវិស័យអប់រំឥស្លាមកម្ពុជាស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលក្នុងការជ្រើសរើសបុគ្គលិកអប់រំ និងគ្រូបង្រៀន

បន្ថែម ស្នើរៀបចំវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពគ្រូបង្រៀនខ្មែរឥស្លាម និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា និងបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលគរុកោសល្យ និងវិក្រឹតការឥស្លាម ស្នើឱ្យមានប្រភពធនធានគាំទ្រ ទាំងធនធានថវិកា និងសម្ភារៈ សម្រាប់គាំទ្រដំណើរការគ្រឹះស្ថានសិក្សាស្នើសុំសាងសង់អាគារសិក្សា និងហេដ្ឋារចនាសម្ព័ន្ធគាំទ្របន្ថែម ស្របតាមតម្រូវការជាក់ស្តែង ស្នើរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រង និងដឹកនាំច្បាស់លាស់ ដើម្បីធានាប្រសិទ្ធភាព និងគុណភាពអប់រំស្នើសុំការទទួលស្គាល់រចនាសម្ព័ន្ធរដ្ឋបាលគណៈគ្រប់គ្រង ដឹកនាំវិស័យអប់រំឥស្លាមគ្រប់លំដាប់ថ្នាក់ទូទាំងប្រទេស ដូចជានាយក នាយករង និងលេខាធិការ ឱ្យសមស្រប តាមនិយាមប្រើប្រាស់បុគ្គលិកអប់រំ ដើម្បីដំណើរការគ្រឹះស្ថានសិក្សាឱ្យមានប្រសិទ្ធភាពស្នើពិនិត្យ និងកែលម្អសៀវភៅសិក្សាគោល ឯកសាររដ្ឋបាលអប់រំ ដើម្បីឱ្យសមស្របតាមស្ថានភាពវិស័យអប់រំឥស្លាមតាមមូលដ្ឋាន ស្នើសុំទទួលស្គាល់កម្មវិធីសិក្សាស្តង់ដាររួម។

## ៤. ទស្សនវិស័យសម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥ និងទិសដៅបន្ត

អនុសាសន៍ **ឯកឧត្តបណ្ឌិត** អូស្មាន ហាស្សាន់ **ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស** ក្នុងពិធីបើកពិធីមហាសន្និបាតអប់រំឥស្លាមឆ្នាំ២០២៥-២០២៣ និងទិសដៅការងារបន្ត ក្រោមប្រធានបទ៖ **«កំណែទម្រង់វិស័យអប់រំឥស្លាមក្នុងបរិបទឌីជីថល»** គឺជាសក្ខីភាពបញ្ជាក់យ៉ាងច្បាស់អំពីគោលបំណងក្នុងការពិនិត្យឡើងវិញនូវវឌ្ឍនភាពការងារសម្រេចបាន ការកែតម្រូវ និងអភិវឌ្ឍគោលនយោបាយអប់រំឥស្លាម បញ្ហាប្រឈម ដំណោះស្រាយនានា និងការដាក់ចេញផែនការយុទ្ធសាស្ត្រ និងទិសដៅអនុវត្តបន្ត ហើយក៏ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់មិនធ្លាប់មានសម្រាប់វិស័យអប់រំឥស្លាមនៅកម្ពុជា និងជាពេលដ៏សមស្របមួយ សម្រាប់បូកសរុបសមិទ្ធផលធំៗ ដែលគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា និងសហគមន៍ឥស្លាមសម្រេចបានរយៈពេលកន្លងទៅ។

**ឯកឧត្តបណ្ឌិតទេសរដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ក្នុងពិធីបើកមហាសន្និបាតអប់រំឥស្លាម ៧ចំណុចសំខាន់ៗ មានដូចខាងក្រោម៖

- ការបន្តពង្រឹង និងអភិវឌ្ឍកម្មវិធីសិក្សាស្តង់ដា គ្រប់កម្រិត និងធ្វើទំនើបកម្ម ឱ្យស្របតាមគោលការណ៍សាសនាឥស្លាម ស្តង់ដាអប់រំជាតិ និងអន្តរជាតិ
- ជំរុញឱ្យរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមគ្រឹះស្ថានអប់រំឥស្លាមឱ្យបានច្បាស់លាស់ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា
- ជំរុញរៀបចំឱ្យមានការទទួលស្គាល់គ្រឹះស្ថានសិក្សាឥស្លាម ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ដែលដំណើរការក្រោមរូបភាពសាលាសហគមន៍មួយចំនួនធំពុំទាន់មានអាជ្ញាបណ្ណទទួលស្គាល់ជាផ្លូវការពីក្រសួង ស្ថាប័នពាក់ព័ន្ធនៅឡើយ
- ជំរុញឱ្យរៀបចំវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពគ្រូបង្រៀនខ្មែរឥស្លាម និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា និងបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលគរុកោសល្យ និងវិក្រឹតការឥស្លាម ។

អនុសាសន៍ ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ម៉ុនឿន** **រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ក្នុងពិធីបិទ មហាសន្និបាតអប់រំឥស្លាមឆ្នាំ២០២៥-២០២៣ និងទិសដៅការងារបន្ត រួមមាន រគាំទ្រនូវទស្សនទាន

ក្នុងការប្រែក្លាយគ្រឹះស្ថានសិក្សាសហគមន៍ទៅជាគ្រឹះស្ថានសិក្សាសាធារណៈតាមរយៈការរៀបចំឱ្យមានជាគ្រឹះស្ថានសិក្សាស្តង់ដា (គ្រឹះស្ថានសិក្សាគំរូ) ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ ដោយធ្វើការវាយតម្លៃ និងជ្រើសរើសគ្រឹះស្ថានសិក្សានៅតាមសហគមន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទាំហេដ្ឋារចនាសម្ព័ន្ធ ផ្នែករឹង និងផ្នែកទន់។ **ឯកឧត្តម** បានស្នើរៀបចំសំណុំបែបបទត្រឹមត្រូវដាក់ជូនក្រសួងអប់រំ យុវជន និងកីឡា ដើម្បីក្រសួងនឹងពិនិត្យលទ្ធភាពក្នុងការដាក់បញ្ចូលគ្រឹះស្ថានសិក្សាឥស្លាមមួយចំនួន ជាគ្រឹះស្ថានសាធារណៈនិងចេញប្រកាសទទួលស្គាល់ជាផ្លូវការ។

**ឯកឧត្តម** បានបន្តលើកទឹកចិត្តឱ្យគ្រប់ភាគីពាក់ព័ន្ធ យកចិត្តទុកដាក់គាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាឧស្សាហកម្ម ការបំពាក់ជំនាញ ឌីជីថល ដូចជា STEM ជាដើម ចាប់ពីនៅគ្រប់កម្រិតសិក្សា ព្រមទាំងគាំទ្រការផ្តល់អាហារូបករណ៍ និងបង្កលក្ខណៈងាយស្រួលដល់យុវជនឆ្នើម ឱ្យទទួលបានការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមគ្រប់រូបភាព ទាំងសាលារៀនរដ្ឋ សហគមន៍ និងឯកជន។ ជាងនេះទៅទៀត យើងត្រូវបន្តចូលរួមយកចិត្តទុកដាក់ជាមួយរាជរដ្ឋាភិបាលលើការពង្រីកចំនួនសាលារៀននៅគ្រប់កម្រិត និងការសាងសង់អគារសិក្សាថ្មី ព្រមទាំងជួសជុលអគារសិក្សាទ្រុឌទ្រោម សាងសង់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បណ្ណាល័យ និងបន្ទប់កុំព្យូទ័រជាដើម។

**ឯកឧត្តមបណ្ឌិតសភាចារ្យ** បានលើកឡើងនូវអនុសាសន៍សំខាន់ៗជូនអង្គមហាសន្និបាត ដើម្បីយកធ្វើជាមូលដ្ឋានពិចារណា និងរៀបចំជាធាតុចូលបន្ថែម សម្រាប់អនុវត្តក្នុងទិសដៅឆ្នាំសិក្សាថ្មីនេះ និងឆ្នាំបន្តបន្ទាប់ទៀត ឱ្យកាន់តែទទួលបានលទ្ធផលល្អប្រសើរ ក្នុងស្មារតីបន្តលើកស្ទួយ និងអភិវឌ្ឍន៍វិស័យអប់រំកម្ពុជា ជាពិសេសវិស័យអប់រំឥស្លាម ឱ្យឈានទៅសម្រេចបានតាមគោលដៅនៃគោលនយោបាយអភិវឌ្ឍវិស័យអប់រំ រយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយត្រូវបន្តយកចិត្តទុកដាក់ខ្ពស់លើការងារសំខាន់ៗ ដូចជា ៖

- កាអនុវត្តកំណែទម្រង់នៅគ្រប់កម្រិតសិក្សា ដោយមានកំណត់សូចនាករ និងសមិទ្ធកម្មច្បាស់លាស់
- ការពង្រឹងអភិបាលកិច្ច
- ការលើកកម្ពស់គុណវុឌ្ឍគ្រូ
- ការកែលម្អ និងរៀបចំកម្មវិធីសិក្សាស្តង់ដារួម
- ការកែលម្អធនធានសិក្សា និងសៀវភៅសិក្សាគោល
- ការប្រើប្រាស់បច្ចេកវិទ្យា
- ការអនុវត្តវិធីសាស្ត្របង្រៀនបែបទំនើប
- ការរួមបញ្ចូលកម្មវិធីស្រាវជ្រាវដោយផ្តោតលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និង
- ការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជាដើម។

## ៥. វិស័យអប់រំឥស្លាមឆ្លើយតបទៅនឹងបញ្ហាប្រឈម

តាមរយៈមហាសន្និបាតអប់រំឥស្លាមឆ្នាំ២០២៥-២០២៣ និងទិសដៅការងារបន្ត ក្រោមប្រធានបទ៖ «**កំណែទម្រង់វិស័យអប់រំឥស្លាមក្នុងបរិបទឌីជីថល**» ក្នុងរយៈពេល ០២ថ្ងៃ ចាប់ពីថ្ងៃទី៥ ដល់ទី៦ ខែមីនា ឆ្នាំ២០២៤ ដោយផ្តោតលើសំណូមពរទាំងឡាយដែលបុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធបានលើកឡើង និងលទ្ធផលនៃកិច្ចពិភាក្សាក្នុងស

ន្និបាតពេញអង្គ គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា បានដាក់ចេញនូវផែនការអាទិភាព ចំនួន ៩ ដើម្បីលើកម្ពស់វិស័យអប់រំឥស្លាមរួមមាន៖

### អាទិភាពទី១៖ ការពង្រឹងស្ថាប័នអប់រំឥស្លាម

- ជំរុញឱ្យមានការបង្កើតគ្រឹះស្ថានសិក្សាឥស្លាមកាន់តែច្រើនឡើងនៅទូទាំងប្រទេស តាមតម្រូវការជាក់ស្តែងរបស់សហគមន៍
- វិនិយោគលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធនៃគ្រឹះស្ថានអប់រំឥស្លាមដែលមានស្រាប់ ដើម្បីបង្កើតបរិយាកាសសិក្សាដែលអំណោយផល
- រៀបចំឱ្យមានប្រព័ន្ធអប់រំឥស្លាមស្តង់ដា មានការទទួលស្គាល់ទាំងគ្រឹះស្ថានអប់រំឥស្លាម និងកម្រិតបណ្តុះបណ្តាល ជាលក្ខណៈជាតិ និងអន្តរជាតិ។

### អាទិភាពទី២៖ ការអភិវឌ្ឍកម្មវិធីសិក្សាឥស្លាម

- អភិវឌ្ឍកម្មវិធីសិក្សាស្តង់ដា គ្រប់កម្រិត និងធ្វើទំនើបកម្ម ឱ្យស្របតាមគោលការណ៍សាសនាឥស្លាម ស្តង់ដាអប់រំជាតិ និងអន្តរជាតិ
- ការរៀបចំវិធីសាស្ត្របង្រៀនថ្មី៖ ជំរុញការស្រាវជ្រាវ និងពង្រឹងជំនាញវិជ្ជាជីវៈគ្រូបង្រៀន អភិវឌ្ឍវិធីសាស្ត្របង្រៀនប្រកបដោយភាពច្នៃប្រឌិត ស្របតាមបរិបទថ្មី ។

### អាទិភាពទី៣៖ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន

- រៀបចំគោលនយោបាយស្តីពី ការអភិវឌ្ឍគ្រូបង្រៀនឥស្លាមឱ្យមានសមត្ថភាព គុណភាព ក្នុងការបំពេញការងារឱ្យទទួលបានជោគជ័យតម្រូវឱ្យមានយុទ្ធវិធី និងសកម្មភាពអនុវត្តច្បាស់លាស់មួយចំនួនដូចជា៖
- កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ៖ បង្កើតកម្មវិធីបណ្តុះបណ្តាល គរុកោសល្យ ចំណេះដឹងមុខវិជ្ជា ជំនាញភាសា វិធីសាស្ត្រអប់រំ និងការស្រាវជ្រាវ ។

### អាទិភាពទី៤៖ ការបញ្ចូលបច្ចេកវិទ្យា

ចាប់យក បច្ចេកវិទ្យាក្នុងការងារអប់រំឥស្លាម ដោយរៀបចំឱ្យមានបន្ទប់កុំព្យូទ័រ បំពាក់អ៊ីនធឺណិត បង្កើតបរិស្ថានសមរម្យសម្រាប់ការអប់រំឌីជីថល ដើម្បីបង្កើនការបង្រៀន និងការរៀន។

### អាទិភាពទី៥៖ ការចូលរួមរបស់សហគមន៍

បន្តជំរុញគ្រប់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាឱ្យរៀបចំឱ្យមានគណៈកម្មការទ្រទ្រង់គ្រឹះស្ថានសិក្សា ដោយសហកាជាមួយអាជ្ញាធរមូលដ្ឋាន ចាស់ព្រឹទ្ធាចារ្យ និងអាណាព្យាបាលសិស្ស ដើម្បីអភិវឌ្ឍគ្រឹះស្ថានសិក្សា និងបង្កើនលទ្ធផលសិក្សារបស់សិស្ស។

### អាទិភាពទី៦៖ ការស្រាវជ្រាវ និងការអភិវឌ្ឍ

លើកកម្ពស់ការស្រាវជ្រាវក្នុងការអប់រំឥស្លាមលើវិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាព ការអភិវឌ្ឍកម្មវិធីសិក្សា និងនវានុវត្តន៍ការអប់រំ។

### អាទិភាពទី៧៖ ការធានាគុណភាព និងការត្រួតពិនិត្យ

បង្កើតក្របខណ្ឌធានាគុណភាព ស្តង់ដានៃការអប់រំកីឡា អនុវត្តដំណើរការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ ដើម្បី ប្រសិទ្ធភាពនៃកំណែទម្រង់នានា។

**អាទិភាពទី៨៖ កិច្ចសហការអន្តរជាតិ ការផ្តល់មូលនិធិ និងការគាំទ្រ**

ស្វែងរកកាល្លានុវត្តភាពនានាសម្រាប់កិច្ចសហប្រតិការអន្តរជាតិ និងភាពជាដៃគូដើម្បីបង្កើនគុណភាពនៃការអប់រំកីឡាមនៅកម្ពុជា និងសហការជាមួយស្ថាប័នអប់រំកីឡា និងអង្គការ សមាគមនានា ជុំវិញពិភពលោក ដើម្បីចែករំលែកឧត្តមានុវត្តន៍ ផ្លាស់ប្តូរចំណេះដឹង និងវប្បធម៌ទៅវិញទៅមក។

**អាទិភាពទី៩៖ ទស្សនទានប្រែក្លាយគ្រឹះស្ថានសិក្សាសហគមន៍ទៅជាគ្រឹះស្ថានសិក្សាសាធារណៈ**

បង្កើតជាសាខាគ្រឹះស្ថានសិក្សាអាន់នៀកម៉ះនៅតាម រាជធានី ខេត្ត ដោយប្រសិទ្ធនាមឈ្មោះ **«គ្រឹះស្ថានសិក្សាអាន់នៀកម៉ះ សម្តេចតេជោ»** ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ ដោយធ្វើការវាយតម្លៃ និងជ្រើសរើសគ្រឹះស្ថានសិក្សានៅតាមសហគមន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ជាពិសេសផ្នែករឹង (ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារបន្ទប់សិក្សា) និងផ្នែកទន់ (ធនធាននានា) និងការរៀបចំជាគ្រឹះស្ថានសិក្សាស្តង់ដា (គ្រឹះស្ថានសិក្សាគំរូ)។

## ៦. សេចក្តីសន្និដ្ឋាន

មហាសន្និបាតបូកសរុបការងារអប់រំកីឡាម ឆ្នាំ២០១៥-២០២៣ និងទិសដៅការងារបន្ត ក្រោមប្រធានបទ៖ **«កំណែទម្រង់វិស័យអប់រំកីឡាមក្នុងបរិបទឌីជីថល»** បានបញ្ជាក់ពីភាពជោគជ័យក្នុងការសម្រេចបាននូវសមិទ្ធផលជាច្រើន ជាពិសេសក្រោយពីរាជរដ្ឋាភិបាលកម្ពុជា បានបញ្ចូលគ្រូបង្រៀនខ្មែរកីឡាមជាគ្រូក្របខណ្ឌនៃក្រសួងអប់រំ យុវជន និងកីឡា និងផ្តល់នូវអនុសាសន៍ល្អៗជាច្រើនសម្រាប់អនុវត្តនៅទិសដៅបន្ទាប់ទៀត។

# ឯកសារទស្សនទាន

## មហាសន្និបាតបូកសរុបការងារអប់រំឥស្លាម ឆ្នាំ២០១៥-២០២៣ និងទិសដៅបន្ត

### ក្រោមប្រធានបទ៖ «កំណែទម្រង់វិស័យអប់រំឥស្លាមក្នុងបរិបទឌីជីថល»

រាជធានីភ្នំពេញ ថ្ងៃទី៥-៦ ខែមីនា ឆ្នាំ២០២៤

វិទ្យាស្ថានជាតិអប់រំ

## ១.សេចក្តីផ្តើម

វិស័យអប់រំ ជាស្នូលនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ក្នុងនោះដែរ ការអប់រំឥស្លាមជាកាតព្វកិច្ចសំខាន់របស់ជនមុស្លីមគ្រប់រូប ផ្សារភ្ជាប់នឹងជីវភាពរស់នៅ វប្បធម៌ អរិយធម៌ និងការប្រតិបត្តិជំនឿសាសនាយ៉ាងតត់មុត ដែលជាផ្នែកមួយដើរតួនាទីសំខាន់សម្រាប់អប់រំកាយ-ចិត្ត ដើម្បីជានាជីវិតរស់នៅក្នុងសង្គមប្រកបដោយសេចក្តីសុខ និងរួមចំណែកដល់ការអភិវឌ្ឍសង្គមជាតិប្រកបដោយចីរភាព។ ក្រោយឆ្លងកាត់សម័យសង្គ្រាមជាច្រើនសម័យកាល គ្រូបង្រៀន និងអតីតសិស្សឥស្លាមកម្ពុជាដែលនៅរស់រានមានជីវិតពីការកាប់សម្លាប់ក្នុងរបបពលពត បានចាប់បង្រៀនគម្ពីរអាល់គួរអាន និងសុណ្ណះ (មាគ៌ារបស់**ព្យាការីមូហាំម៉ាត់**) ដល់កូនចៅនៅតាមសហគមន៍ ដោយប្រើប្រាស់ចំណេះដឹងដែលមានស្រាប់របស់ខ្លួន បង្រៀនសិស្សតាមតំបន់នីមួយៗ ក្នុងរូបភាពស្ម័គ្រចិត្ត និងគ្មានអាគារសិក្សាត្រឹមត្រូវ។ ស្ថិតក្រោមម្លប់សន្តិភាព នៃប្រទេសជាតិ និងដោយមានការបើកទូលាយពីរាជរដ្ឋាភិបាលកម្ពុជា សហគមន៍ឥស្លាមកម្ពុជាបានចាប់ផ្តើមខិតខំពង្រឹងនូវប្រព័ន្ធអប់រំនៅតាមមូលដ្ឋាន និងធ្វើការទំនាក់ទំនងជាមួយសហគមន៍ឥស្លាមនៅតាមបណ្តាប្រទេសជាមិត្តក្នុងតំបន់ និងអន្តរជាតិ និងអង្គការ សមាគមដែលមានចរឹកឥស្លាមនានា ដើម្បីអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាជាបន្តបន្ទាប់។

ជាទំព័រប្រវត្តិសាស្ត្រថ្មីមួយសម្រាប់សហគមន៍ឥស្លាម នៅឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** ដោយមើលឃើញពីការលំបាក និងតម្រូវការចាំបាច់របស់សហគមន៍ឥស្លាមកម្ពុជា **សម្តេចតេជោ** បានបានសម្រេចផ្តល់ជូនដល់សហគមន៍ឥស្លាមនូវគ្រូបង្រៀនខ្មែរឥស្លាមចំនួន ១,៥០០នាក់ ចូលក្របខណ្ឌរដ្ឋ នៃក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងរយៈពេលនៃដំណើរការវិស័យអប់រំឥស្លាមកន្លងមកនេះ ថ្នាក់ដឹកនាំទទួលបន្ទុក និងក្រុមការងារលេខាធិការដ្ឋានអប់រំឥស្លាមសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត បានចុះត្រួតពិនិត្យតាមដានយ៉ាងយកចិត្តទុកដាក់នូវការងារបង្រៀន និងរៀននៅតាមសាលារៀនសហគមន៍ និងបានធ្វើបច្ចុប្បន្នភាពការងារជាប្រចាំ ដើម្បីក្តាប់បាននូវវឌ្ឍនភាពការងារ និងបញ្ហាប្រឈមនានា។

ដើម្បីបូកសរុបការងារ និងពិនិត្យអំពីវឌ្ឍនភាព ស្ថានភាពវិស័យអប់រំឥស្លាមនៅកម្ពុជា រយៈពេលកន្លងមកក្រោយការដាក់បញ្ចូលគ្រូបង្រៀនខ្មែរឥស្លាមជាមន្ត្រីរាជការស៊ីវិលនៃក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងឆ្លុះបញ្ចាំង បញ្ហាប្រឈម និងដំណោះស្រាយ និងលើកទិសដៅការងារដើម្បីអភិវឌ្ឍវិស័យអប់រំឥស្លាមកម្ពុជា គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា សហការជាមួយសមាគមគ្រូបង្រៀនខ្មែរឥស្លាម នឹងរៀបចំមហាសន្និបាតបូកសរុបការងារវិស័យអប់រំឥស្លាម ឆ្នាំ២០១៥-២០២៣ និងលើកទិសដៅបន្ត ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៥ ដល់ទី៦ ខែមីនា ឆ្នាំ២០២៤ នៅវិទ្យាស្ថានជាតិអប់រំ។

## ២. សមាសភាពចូលរួម

សមាសភាពអ្នកចូលរួមមហាសន្និបាត មកពីវិស័យអប់រំគ្រប់លំដាប់ថ្នាក់ ថ្នាក់ដឹកនាំឥស្លាមតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងតាមបណ្តារាជធានី-ខេត្តទូទាំងប្រទេស និងតំណាងអង្គការសមាគមពាក់ព័ន្ធនានា ដោយអ្នកចូលរួមផ្ទាល់ក្នុងអង្គមហាសន្និបាតមានប្រមាណ ៥០០នាក់ និងភ្ញៀវកិត្តិយសប្រមាណ១០០នាក់ និងមានអ្នកចូលរួមតាមប្រព័ន្ធអនឡាញប្រមាណ១,០០០នាក់ ។

៣. វត្ថុបំណង

មហាសន្និបាតប្រារព្ធឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ពិនិត្យវឌ្ឍនភាពសមិទ្ធផលការងារ បញ្ហាប្រឈម ដំណោះស្រាយ និងលើកទិសដៅការងារបន្ត
- វេទិកាពិភាក្សាលើស្ថានភាពអប់រំកាយ ទិសដៅ និងការរៀបចំអនុវត្តគោលនយោបាយអប់រំកាយ
- ផ្តល់អនុសាសន៍សំខាន់ៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២៤ ឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់ទី១ របស់រាជរដ្ឋាភិបាល។

## ៤. កម្មវិធីអម

ដើម្បីបង្ហាញអំពីសមទ្ធផលនានា ដែលអនុវត្តបានកន្លងមក និងដើម្បីញ៉ាំងឱ្យដំណើរប្រព្រឹត្តទៅនៃមហាសន្និបាតកាន់តែរលូន គណៈកម្មការរៀបចំមហាសន្និបាតនឹងរៀបចំកម្មវិធីអមសំខាន់ៗមួយចំនួនដូតទៅ៖

១. ការតាំងពិពណ៌ដាក់បង្ហាញអំពីសមទ្ធផលអប់រំ របស់គ្រឹះស្ថានសិក្សាសហគមន៍ និងអង្គការ សមាគមមួយចំនួន ដើម្បីបង្ហាញជូនថ្នាក់ដឹកនាំ និងអង្គមហាសន្និបាតទស្សនាឈ្វេងយល់។

២. ការប្រឡងជ្រើសរើស ផ្តល់រង្វាន់ស្នាដៃតែងនិពន្ធខុទ្ទកៈ ជ័យលាភីទូទាំងប្រទេស ដើម្បីរួមចំណែកលើកស្ទួយវិស័យអប់រំនៅកម្ពុជា ។

៣. ការវាយតម្លៃជ្រើសរើសសាលាស្អាតទូទាំងប្រទេស ដើម្បីផ្តល់ជូនពានរង្វាន់ក្នុងមហាសន្និបាត។

## ៥.ដំណើរការមហាសន្និបាត

មហាសន្និបាតបូកសរុបការងារអប់រំកាយ ឆ្នាំ២០១៥-២០២៣ និងទិសដៅការងារបន្ត ក្រោមប្រធានបទ៖ **«កំណែទម្រង់វិស័យអប់រំកាយក្នុងបរិបទឌីជីថល»** នឹងប្រារព្ធឡើងរយៈពេល ០២ ថ្ងៃ ចាប់ពីថ្ងៃទី៥ ដល់ទី៦ ខែមីនា ឆ្នាំ២០២៤ នៅវិទ្យាស្ថានជាតិអប់រំ ។ ពិធីបើកមហាសន្និបាតស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត** អូស្នាន ហាស្សាន់ **ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស** និងពិធីបិទមហាសន្និបាតស្ថិតក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ម៊ុនឿន រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**។ កិច្ចពិភាក្សាពេញអង្គនឹងប្រព្រឹត្តទៅដោយមានវេទិកាពិភាក្សាចំនួនពីរ និងមានបទបង្ហាញពាក់ព័ន្ធប្រធានសំខាន់មួយចំនួន ដោយមានការចូលរួមពីវាគ្មិនជំនាញជាតិ និងអន្តរជាតិ ប្រកបដោយលក្ខណៈសម្បត្តិខ្ពស់ មានសំនួនវោហារទាក់ទាញ និងមានពិសោធន៍ច្រើនពាក់ព័ន្ធនឹងវិស័យអប់រំ។

## ៦. ការងារត្រូវអនុវត្តក្រោយមហាសន្និបាត

- រៀបចំរបាយការណ៍មហាសន្និបាតដាក់ជូនថ្នាក់ដឹកនាំពាក់ព័ន្ធ និងផ្សព្វផ្សាយដល់ថ្នាក់ក្រោមជាតិ
- រៀបចំផែនការយុទ្ធសាស្ត្រ និងគោលនយោបាយអប់រំកាយ ក្នុងការអនុវត្តរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីធ្វើកំណែទម្រង់វិស័យអប់រំកាយឱ្យកាន់តែមានប្រសិទ្ធភាព។

## ៧. ការឧបត្ថម្ភ

គណៈកម្មការរៀបចំមហាសន្និបាតបូកសរុបការងារអប់រំកាយ ឆ្នាំ២០១៥-២០២៣ និងទិសដៅការងារបន្ត សូមបើកចំហ និងទទួលស្វាគមន៍រាល់ការចូលរួមឧបត្ថម្ភទាំងឡាយ ទាំងថវិកា និងស្មារតី ដើម្បីរួមចំណែកឱ្យដំណើការ

មហាសន្និបាតប្រព្រឹត្តទៅដោយរលូន ប្រកបដោយជោគជ័យ ជាផ្លែផ្កាសម្រាប់សហគមន៍ឥស្លាម ជាពិសេសដើម្បីអភិវឌ្ឍវិស័យអប់រំឥស្លាមកម្ពុជា។ មហាសន្និបាតអប់រំឥស្លាមនេះ ជាឱកាសសម្រាប់សាធារណៈជន អង្គការ សមាគម និងវិស័យឯកជននានា អាចបង្ហាញអំពីការយកចិត្តទុកដាក់ខ្ពស់ចំពោះវិស័យអប់រំ លើកស្ទួយធនធានមនុស្ស ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គមជាតិប្រកបដោយចីរភាព។

គណៈកម្មការរៀបចំមហាសន្និបាត សូមអំពាវនាវដល់ **សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី សប្បុរសជនជាតិ អន្តរជាតិ ក្រុមហ៊ុនឯកជន សមាគម អង្គការមិនមែនរដ្ឋាភិបាល** និង**សាធារណៈជនទាំងអស់** មេត្តាចូលរួមជួយឧបត្ថម្ភគាំទ្រ ដល់មហាសន្និបាត ដើម្បីផ្គត់ផ្គង់លើការចំណាយផ្សេងៗក្នុងកិច្ចដំណើការកម្មវិធីទាំងមូល។

សូមមេត្តាចូលរួមឧបត្ថម្ភតាមរយៈ ៖



**ឧបសម្ព័ន្ធ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កម្មវិធី

## មហាសន្និបាតបូកសរុបការងារអប់រំឥស្លាម ឆ្នាំ២០១៩ ២០២៣ និងទិសការងារដៅបន្ត

**ក្រោមប្រធានបទ៖ «កំណែទម្រង់វិស័យអប់រំឥស្លាមក្នុងបរិបទឌីជីថល»**

រាជធានីភ្នំពេញ ពីថ្ងៃទី៥ ដល់ទី៦ ខែមីនា ឆ្នាំ២០២៤

វិទ្យាស្ថានជាតិអប់រំ

| **ថ្ងៃទី១៖ ទី០៥ ខែមីនា ឆ្នាំ២០២៤** | |
|---|---|
| **ពេលព្រឹក** | |
| ម៉ោង 07:00-07:30 | - ចុះឈ្មោះសមាជិក សមាជិកានៃអង្គមហាសន្និបាត |
| ម៉ោង 07:30-07:45 | - ថ្នាក់ដឹកនាំ អង្គទូត ភ្ញៀវកិត្តិយសជាតិ អន្តរជាតិអញ្ជើញដល់ |
| ម៉ោង 08:00-9:45 | - **ឯកឧត្តមបណ្ឌិត អូស្មាន ហាសាន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អញ្ជើញដល់<br>**ពិធីបើកមហាសន្និបាត**<br>- ប្រកាសហេតុ<br>- គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>- ការសូត្រគម្ពីរអាល់គួរអានុលការីម ដោយ **លោក នី អះម៉ាត់**<br>- របាយការណ៍ស្វាគមន៍របស់ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានសមាគមគ្រូបង្រៀនខ្មែរអ៊ីស្លាមកម្ពុជា<br>- សុន្ទរកថាបើកមហាសន្និបាតដោយ **ឯកឧត្តមបណ្ឌិត អូស្មាន ហាសាន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស |
| ម៉ោង 10:00-12:00 | - **បាឋកថាពិសេស៖ ឧត្តមភាពនៃវិស័យអប់រំឥស្លាមកម្ពុជា** ដោយ **អ្នកឧកញ៉ា សុះ គំរី** ចាងហ្វាងគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា<br>- **គោលការណ៍ណែនាំស្តីពីការពិភាក្សាពេញអង្គ នៃមហាសន្និបាត** ដោយ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។ |
| **ពេលរសៀល**<br>ដឹកនាំដោយថ្នាក់ដឹកនាំគណៈកម្មការ | |
| ម៉ោង 13:30-14:15 | - **សុន្ទរកថាគន្លឹះ ៖ បទពិសោធន៍ការធ្វើកំណែទម្រង់វិស័យអប់រំនៅកម្ពុជា** ដោយ **ឯកឧត្តម កែវ សារ៉ាត់** អតីតមន្ត្រីប្រធានគម្រោងកំណែទម្រង់វិស័យអប់រំនៃធនាគារពិភពលោក |

| | |
|---|---|
| ម៉ោង 14:15-17:00 | **វេទិកាពិភាក្សាទី១៖ ស្ថានភាពអប់រំឥស្លាម**<br>- បទបង្ហាញស្តីពី **ប្រព័ន្ធគ្រប់គ្រងអប់រំឥស្លាមកម្ពុជា** ដោយ **លោក ម៉ាត់ អាល់ពី** ប្រធានការិយាល័យគោលនយោបាយ និងផែនការនៃគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា<br>- បទបង្ហាញស្តីពី **ការអភិវឌ្ឍកម្មវិធីសិក្សាស្តង់ដា** ដោយ **ឯកឧត្តម សឹម ម៉ាត់ទោត** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាមន្រ្តីផ្នែកអភិវឌ្ឍកម្មវិធីសិក្សារបស់គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា<br>- បទបង្ហាញស្តីពី **គំរូកម្មវិធីសិក្សាឥស្លាមប្រទេសឥណ្ឌូនេស៊ី** ដោយ **Prof. Dr.Salamah Agung** ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្រ្តអប់រំនៃសាកលវិទ្យាល័យ **Islam Negeri Syarif Hidayatullah Jakarta**<br>- បទបង្ហាញស្តីពី **ការបណ្តុះបណ្តាលជំនាញវិទ្យាសាស្ត្រ និងឌីជីថលក្នុងសាលារៀន** ដោយ **លោក សឹម ណាសៀត** នាយកសាលាអន្តរជាតិ អាល់រ៉ះម៉ាស់<br>- វេទិកាសំណួរ-ចម្លើយ<br>- សម្របសម្រួលដោយ **លោកបណ្ឌិត ខួន សំណាង** ព្រឹទ្ធបុរសមហាវិទ្យាល័យ ថ្នាក់ក្រោយឧត្តមសិក្សា សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| **ថ្ងៃទី២៖ ទី០៦ ខែមីនា ឆ្នាំ២០២៤** | |
| **ពេលព្រឹក**<br>ដឹកនាំដោយថ្នាក់ដឹកនាំគណៈកម្មការ | |
| ម៉ោង 08:00-10:00 | **វេទិកាពិភាក្សាទី២៖ ទិសដៅការងារអប់រំឥស្លាម**<br>- បទបង្ហាញស្តីពី **បទពិសោធន៍នៃការគ្រប់គ្រងសាលាបឋមសិក្សាឧត្តមូ** ដោយ **ឯកឧត្តម ពឹង គឹមឆេន** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា<br>- បទបង្ហាញស្តីពី **ការចូលរួមរបស់សហគមន៍គាំទ្រសាលារៀន** ដោយ **លោក ទូលាស់ សាម៉អះ** នាយកសាលាអាល់អៀហសាន រាជធានីភ្នំពេញ<br>- វេទិកាសំណួរ-ចម្លើយ<br>- សម្របសម្រួលដោយ **លោកបណ្ឌិត ឈិង ស៊ីថា** អ្នកស្រាវជ្រាវផ្នែកអប់រំ |
| ម៉ោង 10:00-12:00 | - មតិបូកសរុប ដោះស្រាយបញ្ហាគន្លឹះ និងទិសដៅការងារបន្ត ដោយ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| **ពេលរសៀល**<br>**ពិធីបិទមហាសន្និបាត** | |
| ម៉ោង 14:00-14:30 | - ចុះឈ្មោះសមាជិក សមាជិកានៃអង្គមហាសន្និបាត |

| | |
|---|---|
| ម៉ោង 14:30-14:45 | - ថ្នាក់ដឹកនាំ អង្គទូត ភ្ញៀវកិត្តិយសជាតិ អន្តរជាតិអញ្ជើញដល់ |
| ម៉ោង 15:00- | - **ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ម៊ុនឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អញ្ជើញដល់<br>**ចាប់ផ្តើមកម្មវិធី**<br>- ការសូត្រគម្ពីរអាល់គួរអានុលការីម ដោយ **លោក នី អះម៉ាត់**<br>- សុន្ទរកថាស្វាគមន៍ និងរបាយការណ៍បូកសរុបមហាសន្និបាត ដោយ **ឯកឧត្តម ណុះ ស្លេះ រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា**<br>- សុន្ទរកថា និងប្រសាសន៍សំណេះសំណាលរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ម៊ុនឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង **អប់រំ យុវជន និងកីឡា**<br>- ការប្រគល់ពានរង្វាន់ជូនជ័យលាភី សាលារៀនស្អាត ជ័យលាភីស្នាដៃតែងនិពន្ធខុទ្ទពះ និងលិខិតថ្លែងអំណរគុណដល់ដៃគូសហការឧបត្ថម<br>- គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងបិទមហាសន្និបាត<br>- ដំណើរនិវត្តន៍របស់**ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ម៊ុនឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា** |

**កំណត់សម្គាល់៖** គណៈកម្មការសូមរក្សាសិទ្ធិកែប្រែកម្មវិធីនេះក្នុងករណីចាំបាច់។

## ឧបសម្ព័ន្ធទី២ សុន្ទរកថាបើក និងបិទ

- **សុន្ទរកថាបើក**

### ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

# សុន្ទរកថា
# ឯកឧត្តមបណ្ឌិត អូស្មាន ហាសាន់
# ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
# ថ្លែងក្នុងពិធីបើកមហាសន្និបាតបូកសរុបការងារអប់រំឥស្លាម ២០១៥-២០២៣
# និងលើកទិសដៅការងារបន្ត
# វិទ្យាស្ថានជាតិអប់រំ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤

- **អ្នកឧកញ៉ា សុះ អំរី** ចាងហ្វាង នៃគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា
- លោក **ឧកញ៉ាឃ្លូរ ម៉ាត់ សា** មេដឹកនាំសហគមន៍ក្រុមកនអ៊ីម៉ាំសាន់
- ឯកឧត្តម លោកជំទាវ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា ទីប្រឹក្សាជាន់ខ្ពស់រដ្ឋសភា រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សារាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូ
- លោក លោកស្រី អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា
- ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ តំណាងអង្គការ សមាគម វិស័យឯកជន
- គណៈអ៊ីម៉ាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអ៊ីម៉ាំម៉ាស្ជិទ នាយកអប់រំគ្រូបង្រៀនខ្មែរឥស្លាម នាយក នាយិកា លោកគ្រូ អ្នកគ្រូ និងអង្គពិធីទាំងមូលជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានចូលរួមជាអធិបីក្នុងពិធីបើក **«មហាសន្និបាតអប់រំឥស្លាមបូកសរុបការងារអប់រំឥស្លាម ២០១៥-២០២៣ និងលើកទិសដៅការងារបន្ត»**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ**អ្នកឧកញ៉ា សុះ អំរី** ថ្នាក់ដឹកនាំទាំងអស់នៃគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ថ្នាក់ដឹកនាំនៃក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈអ៊ីម៉ាំគ្រប់លំដាប់ថ្នាក់ នាយកអប់រំគ្រូបង្រៀនខ្មែរឥស្លាម នាយក នាយិកា និងគ្រូបង្រៀនខ្មែរឥស្លាម ដែលបានបំពេញការងារយ៉ាងសកម្មក្នុងស្មារតីទទួលខុសត្រូវខ្ពស់ សំដៅជានាឱ្យសិស្ស និស្សិតខ្មែរឥស្លាមទទួលបានលទ្ធផលសិក្សាល្អ ប្រកបដោយចំណេះ និងជំនាញពិតប្រាកដ និងច្បាស់លាស់។

ខ្ញុំក៏សូមសម្ដែងនូវអំណរគុណចំពោះអង្គការជាតិ និងអន្តរជាតិ វិស័យឯកជន និងសប្បុរសជនក្នុង និងក្រៅប្រទេស ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការស្ដារ កសាង និងអភិវឌ្ឍវិស័យអប់រំឥស្លាមនៅកម្ពុជា តាមរយៈការវិនិយោគ ក៏ដូចជាការផ្ដល់នូវជំនួយឧបត្ថម្ភ និងការគាំទ្រគ្រប់បែបយ៉ាង ទាំងធនធានថវិកា សម្ភារៈ និងបច្ចេកទេស នាពេលកន្លងទៅ។

ខ្ញុំសូមវាយតម្លៃខ្ពស់ និងកោតសរសើរដោយស្មោះចំពោះគណៈកម្មការរៀបចំមហាសន្និបាត និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានជម្នះរាល់ការលំបាក ធ្វើឱ្យមហាសន្និបាតនេះលេចជារូបរាងឡើង ដែលជាការបើកផ្លូវមួយសម្រាប់ដំណើរនៃកំណែទម្រង់វិស័យអប់រំឥស្លាមជាបន្តបន្ទាប់។

## អ្នកឧកញ៉ា ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ខ្ញុំមានមោទនភាពខ្ពស់ចំពោះការបោះជំហានឆ្ពោះទៅមុខជានិច្ចនៃវិស័យអប់រំឥស្លាម ដែលបាននិងកំពុងឆ្លើយតបយ៉ាងប្រត្យក្សទៅនឹងតម្រូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា នាពេលពុបច្ចុប្បន្ន និងអនាគត។ ជាក់ស្ដែង **«មហាសន្និបាតអប់រំឥស្លាមបូកសរុបការងារអប់រំឥស្លាម ២០១៥-២០២៣ និងលើកទិសដៅការងារបន្ត»** ក្របខណ្ឌទូទាំងប្រទេស ក្រោមប្រធានបទ៖ **«កំណែទម្រង់វិស័យអប់រំឥស្លាមក្នុងបរិបទឌីជីថល»** គឺជាការសក្ខីភាពបញ្ជាក់យ៉ាងច្បាស់អំពីគោលបំណងក្នុងការពិនិត្យឡើងវិញនូវវឌ្ឍនភាពការងារសម្រេចបាន កែតម្រូវ និងអភិវឌ្ឍគោលនយោបាយអប់រំឥស្លាម បញ្ហាប្រឈម ដំណោះស្រាយនានា និងការដាក់ចេញផែនការយុទ្ធសាស្ត្រ និងទិសដៅអនុវត្តបន្ត។

ការគិតគូរដ៏វែងឆ្ងាយ ប្រកបដោយចក្ខុវិស័យច្បាស់លាស់សម្រាប់អភិវឌ្ឍវិស័យអប់រំឥស្លាមនេះ គឺមិនមែនសាមញ្ញពេកនោះទេ ប៉ុន្តែដោយឈរលើការប្ដេជ្ញាចិត្ត ឆន្ទៈ និងការចូលរួមពីគ្រប់ភាគី យើងមានក្ដីសង្ឃឹមយ៉ាងមុតមាំថា វិស័យអប់រំឥស្លាមនៅកម្ពុជា នឹងចូលរួមចំណែកយ៉ាងសកម្ម និងកាន់តែមានសារៈសំខាន់ក្នុងការអប់រំ ការបណ្ដុះបណ្ដាល និងការផ្ដល់ចំណេះដឹងដល់សិស្សានុសិស្សនៅក្នុងសហគមន៍ខ្មែរឥស្លាម ដើម្បីឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខដឹកនាំ ជាបញ្ញវន្តមួយរូបប្រកបដោយសក្តានុពល និងថាមពលខ្លាំងក្លា ដែលដាក់ចេញនូវមុំអាទិភាពទី១ គឺ មនុស្ស ដើម្បីជានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

## អ្នកឧកញ៉ា ឯកឧត្តម លោកជំទាវ លោក លោកស្រី!

សមិទ្ធផលគ្រប់វិស័យកំពុងរីកដុះដាលជាបន្តបន្ទាប់នេះ គឺស្តែងចេញពីប្រទេសជាតិកំពុងស្ថិតក្នុងសុខសន្តិភាព ស្ថិរភាពនយោបាយ និងការឯកភាពជាតិតែមួយ ក្រោមការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា បានស្តាបនាសង្គមមួយមានសេចក្តីថ្លៃថ្នូរ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងអភិវឌ្ឍប្រទេសប្រកបដោយចីរភាព។

ប្រទេសកម្ពុជាបានឆ្លងកាត់ភ្លើងសង្គ្រាមជាច្រើនទសវត្ស ដែលបង្កវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋ និងមនុស្សជំនាន់ក្រោយ។ របបប្រល័យពូជសាសន៍ ប៉ុល ពត បានបំផ្លិចបំផ្លាញអាយុជីវិត និងហេដ្ឋារចនាសម្ព័ន្ធជាតិស្ទើរទាំងស្រុង។ ប្រជាជនស្លូតត្រង់ជាង ៣លាននាក់ បានស្លាប់បាត់បង់អាយុជីវិតយ៉ាងអណោចអធ័ម និងអយុត្តិធម៌ជាទីបំផុត។ ធនធានមនុស្ស ជា សាស្ត្រាចារ្យ បញ្ញវន្ត គ្រូបង្រៀន និងអ្នកចេះដឹង ដែលជាមូលធនរបស់ជាតិ ក៏ត្រូវបានបាត់បង់ស្ទើរគ្មានសល់។ ក្រោយថ្ងៃរំដោះ ១៩៧៩ ប្រទេសកម្ពុជាត្រូវបានស្តារឡើងវិញ តាមរយៈការប្រមូលធនធានដែលនៅសេសសល់ដើម្បីរួមគ្នាកសាងឡើងវិញ។ ជាក់ស្តែង ការកសាងខឿនសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អក្សរសាស្ត្រ សាសនា និងទំនៀមទម្លាប់ប្រពៃណី ដែលត្រូវបានបំផ្លិចបំផ្លាញដល់កម្រិតសូន្យ គឺជាអាទិភាពរួមមាន ការជួសជុល ការស្តារ ការការពារ និងការកសាងលើគ្រប់វិស័យឡើងវិញ ត្រូវបានធ្វើឡើងជាបន្តបន្ទាប់។ ក្នុងនោះវិស័យ អប់រំ ត្រូវបានគិតគូរជាអាទិភាព សាលារៀន វត្តអារាម និងថ្នាក់រៀនត្រូវបានរៀបចំឱ្យដំណើរការឡើងវិញ។

៤៥ឆ្នាំក្រោយ គឺកម្ពុជាបានប្រែក្លាយពីប្រទេសដែលសេសសល់ពីគំនរផេះផង់នៃសង្គ្រាមស៊ីវិល មកជាប្រទេសមួយមានការអភិវឌ្ឍជាលំដាប់ ដែលធ្វើឱ្យប្រទេសកម្ពុជាកែប្រែមុខមាត់ថ្មី ជាប្រទេសមានសេដ្ឋកិច្ចលូតលាស់លឿន។ កម្ពុជាបានខិតខំរើខ្លួនចេញរួចផុតពីប្រទេសក្រីក្រ គឺប្រទេសដែលគ្មានអ្វីសោះ មកជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ព្រមទាំងកំពុងអភិវឌ្ឍឱ្យក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ ២០៥០។ ជាមួយនេះ គួរកត់សម្គាល់ថា វឌ្ឍនភាពនៃវិស័យអប់រំនេះ ពិតជាបានរួមចំណែកយ៉ាងសំខាន់ដល់ការរីកលូតលាស់ នៃសង្គម-សេដ្ឋកិច្ចកម្ពុជា។ ក្នុងនោះ កម្ពុជាត្រូវបានទទួលស្គាល់ជាប្រទេស ដែលមានការអភិវឌ្ឍឆាប់រហ័ស ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទាំងផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសេវាកម្ម។

សម្រាប់សហគមន៍ឥស្លាមនៅកម្ពុជាមានភ័ព្វសំណាងខ្ពស់ ដោយបានរួមរស់ជាមួយប្រជាពលរដ្ឋខ្មែរយ៉ាងសុខដុមរមនា មានសិទ្ធិ និងកាតព្វកិច្ចដូចគ្នាចំពោះមុខច្បាប់ គ្មានការរើសអើង ពិសេសមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសខាងជំនឿសាសនាដែលខ្លួនពេញចិត្ត។ ខុសពីវាសនាជនមូស្លិមនៅបណ្តាប្រទេសជិតខាងមួយចំនួន និងពិភពលោក។ រាជរដ្ឋាភិបាលកម្ពុជាតែងបានយកចិត្តទុកដាក់ និងលើកតម្កើងសិទ្ធិសេរីភាពខាងជំនឿសាសនារបស់ប្រជាពលរដ្ឋ និងការអប់រំ។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់នូវសមិទ្ធផលធំៗ ជាច្រើនសម្រាប់សហគមន៍ និយាយជារួម និងនិយាយដោយឡែក វិស័យអប់រំ ជាអាទិ៍៖

- **សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បានផ្តល់អំណោយអាគារសិក្សាដល់សហគមន៍ឥស្លាម ចំនួន ២២ខ្នង ស្មើនឹង ២៤៤បន្ទប់ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម កំពត និងខេត្តត្បូងឃ្មុំ
- អនុញ្ញាតឱ្យសិស្ស និស្សិតខ្មែរឥស្លាមស្លៀកពាក់ប្រពៃណីរបស់ខ្លួននៅក្នុងពេលរៀននៅគ្រឹះស្ថានអប់រំសាធារណៈ និងឯកជន
- អនុញ្ញាតជាគោលការណ៍ឱ្យបុរសពាក់កាតឹប និងស្ត្រីខ្មែរឥស្លាមទទូរក្រមារ ពេលធ្វើ លិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ ឬថតរូបសម្រាប់ឯកសាររដ្ឋបាលផ្សេងៗ
- អនុញ្ញាតជាគោលការណ៍ ដើម្បីបញ្ចូលគ្រូបង្រៀនខ្មែរឥស្លាម ចំនួន ១៥០០នាក់ ទៅក្នុងក្របខណ្ឌគ្រូបង្រៀន នៃក្រសួងអប់រំ យុវជន និងកីឡា
- បាននិងកំពុងរៀបចំគោលនយោបាយស្តីពី «ការអភិវឌ្ឍវិស័យអប់រំឥស្លាម និងផែនការសកម្មភាព»
- អនុញ្ញាតគោលការណ៍ឱ្យគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ដំណើរការមណ្ឌលប្រឡងមធ្យមសិក្សាទុតិយភូមិផ្នែកសិក្សាសាសនាឥស្លាមនៅកម្ពុជា (STAM) ដោយបានចុះអនុស្សរណៈជាមួយស្ថានប័នអប់រំនៃប្រទេសម៉ាឡេស៊ី
- សម្តេចតេជោ អំពាវនាវ និងផ្តល់អនុសាសន៍ដល់គ្រឹះស្ថានសិក្សារដ្ឋ និងឯកជនកម្រិតឧត្តមសិក្សា ត្រូវរៀបចំឱ្យមានកន្លែងថ្វាយបង្គំដើម្បីបង្កលក្ខណៈងាយស្រួលដល់សិស្ស និស្សិតជាមុស្លិម
- ដោះស្រាយ និងជួយអន្តរាគមន៍បានទាន់ពេលវេលាចំពោះសិស្ស និស្សិតឥស្លាម ដែលកំពុងសិក្សានៅបរទេស ហើយមានបញ្ហាផ្សេងៗ ដូចជាការបះបោរ សង្គ្រាមស៊ីវិល ឱ្យបានវិលត្រលប់មកមាតុភូមិវិញដោយសុវត្ថិភាព ។ល។

ឆ្នាំ២០១៥ ជាទំព័រប្រវត្តិសាស្ត្រថ្មីមួយទៀតសម្រាប់សហគមន៍ឥស្លាមកម្ពុជា ដែលរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចផ្តល់ជូនដល់សហគមន៍ឥស្លាមកម្ពុជានូវគ្រូបង្រៀនខ្មែរឥស្លាមចំនួន ១ ៥០០នាក់ ចូលក្របខណ្ឌរដ្ឋ នៃក្រសួងអប់រំ យុវជន និងកីឡា ដោយ **សម្តេច** បានមើលឃើញពីការលំបាក និងតម្រូវការចាំបាច់របស់សហគមន៍ឥស្លាមកម្ពុជា។

ផ្អែកលើសមិទ្ធផល និងការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល សហគមន៍ឥស្លាមកម្ពុជាបានចាប់ផ្តើមពង្រឹងនូវប្រព័ន្ធអប់រំនៅតាមមូលដ្ឋាន ដោយមានការបើកទូលាយពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើទំនាក់ទំនងជាមួយសហគមន៍ឥស្លាមនៅតាមបណ្តាប្រទេសជាមិត្តក្នុងតំបន់ និងជុំវិញសកលលោក ធ្វើឱ្យសហគមន៍ឥស្លាមមានលទ្ធភាពជាងមុន មានអាគារសិក្សា កសាងបានសមិទ្ធផលវិស័យអប់រំ បានចូលរួមចំណែកអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាជាបន្តបន្ទាប់។

ខ្ញុំជឿជាក់ថា មហាសន្និបាតរបស់យើងនឹងប្រែក្លាយអាទិភាពមួយចំនួនដែលយើងកំពុងប្រឈម និងសំណូមពរ ដូចជា ការអភិវឌ្ឍកម្មវិធីសិក្សាស្របតាមបរិបទថ្មី ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងឱ្យបានច្បាស់លាស់ ការទទួលស្គាល់គ្រឹះស្ថានសិក្សាពីស្ថាប័នរដ្ឋ ការបណ្តុះបណ្តាល និងវិក្រឹតការ ការកៀរគរប្រភពធនធាន ការរៀបចំ

ប្រព័ន្ធអធិការកិច្ចឱ្យបានត្រឹមត្រូវ តម្រូវការគ្រូ និងរចនាសម្ព័ន្ធដឹកនាំនៅតាមសាលារៀន និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ឱ្យក្លាយទៅជាផែនការយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីសម្រេចបាននូវគោលដៅអប់រំដោយមានកំណត់សូចនាករសមិទ្ធកម្មច្បាស់លាស់។

អង្គមហាសន្និបាតអប់រំឥស្លាម ដែលនឹងដំណើរការនាពេលបន្តិចទៀតនេះ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់មិនធ្លាប់មានសម្រាប់វិស័យអប់រំឥស្លាមនៅកម្ពុជា និងជាពេលដ៏សមស្របមួយ សម្រាប់បូកសរុបសមិទ្ធផលធំៗ ដែលគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា និងសហគមន៍ឥស្លាមសម្រេចបានរយៈពេលកន្លងទៅ ក៏ដូចជាលើកទិសដៅការងារសម្រាប់ឆ្នាំបន្ទាប់ និងសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែងខាងមុខ។ ក្នុងឱកាសនេះ ខ្ញុំសូមលើកចិត្តឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក សមាជិកានៃអង្គមហាសន្និបាតទាំងមូល សូមធ្វើការពិក្សា និងផ្លាស់ប្តូរយោបល់ ចំណេះដឹង និងចំណេះធ្វើ ព្រមទាំងបទពិសោធន៍ និងឧត្តមានុវត្តន៍ល្អៗ ដោយត្រង់ទៅត្រង់មក និងក្នុងស្មារតីស្ថាបនា ដើម្បីរិះរកវិធានការនានា សម្រាប់ឆ្លើយតបទៅនឹងសំណូមពរថ្មីៗនៃការអភិវឌ្ឍសហគមន៍ និងសង្គម-សេដ្ឋកិច្ចកម្ពុជា។ ខ្ញុំមានក្តីរំពឹង និងភាពជឿជាក់យ៉ាងមុតមាំថា អង្គមហាសន្និបាត ដែលនឹងប្រព្រឹត្តទៅរយៈពេលពីរថ្ងៃនេះ នឹងដំណើការដោយរលូន និងទទួលបាននូវផ្លែផ្កា តាមការរំពឹងទុក

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះអ្នកឧកញ៉ា ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និស្សិត និងអង្គមហាសន្និបាតទាំងមូល សូមទទួលបានសូមទទួលបានឥស្លាមពរ គឺ **ស្លាម៉ាត់** (សេចក្តីសុខ) **ពើរ៉កាត់** (ចម្រុងចម្រើន) **រ៉ោះម៉ាត់** (ករុណា) និង**អាហ្វីយ៉ាត់** (សុខភាពល្អបរិបូរណ៍) និងជោគជ័យគ្រប់ភារកិច្ច ជាពិសេសសូមទូអាពី **អល់ឡោះ** ឱ្យយើងទាំងអស់គ្នាបានជួបខែរ៉ាម៉ាឌនដ៏ពិសិដ្ឋនៃសាសនាឥស្លាម ដែលនឹងឈានមកដល់ក្នុងពេលដ៏ខ្លីប៉ុន្មានថ្ងៃខាងមុខនេះ។ ***អាមីន!***

ខ្ញុំសូមប្រកាសបើកជាផ្លូវការនូវ «**មហាសន្និបាតបូកសរុបការងារអប់រំឥស្លាម ២០១៥-២០២៣ និងលើកទិសដៅការងារបន្ត**» ចាប់ពីពេលនេះតទៅ៕

❖ **សុន្ទរកថាបិទ**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# សុន្ទរកថា
## ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
## ថ្លែងក្នុង
## ពិធីបិទមហាសន្និបាតបូកសរុបការងារអប់រំកីឡាតសិល្បៈ ឆ្នាំ២០១៥-២០២៣
## និងលើកទិសដៅការងារបន្ត

វិទ្យាស្ថានជាតិអប់រំ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤

- អ្នកឧកញ៉ាចាងហ្វាង គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា
- ឯកឧត្តម លោកជំទាវ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សាក្រសួង ស្ថាប័ន
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ
- អង្គមហាសន្និបាតទាំងមូលជាទីមេត្រី

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីរីករាយ ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ពីសំណាក់ **ឯកឧត្តបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ចូលរួមជាអធិបតីក្នុងពិធីបិទ "**មហាសន្និបាតបូកសរុបការងារអប់រំឥស្លាម ឆ្នាំ២០១៥-២០២៣ និងលើកទិសដៅការងារបន្ត**" ដែលគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា សហការជាមួយសមាគមគ្រូបង្រៀនខ្មែរឥស្លាម បានរៀបចំឡើងក្នុងរយៈពេល២ថ្ងៃ កន្លងមកនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះអង្គមហាសន្និបាត ដែលមិនត្រឹមតែអាចពិនិត្យលទ្ធផលសម្រេចបានលើការងារអប់រំឥស្លាមទាំងមូលប៉ុណ្ណោះទេ ថែមទាំងផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធ បានយល់ជ្រួតជ្រាប និងបន្តចូលរួមអនុវត្តកម្មវិធីកែទម្រង់អប់រំកាន់តែស៊ីជម្រៅ ក្នុងស្មារតីធ្វើឱ្យវិស័យអប់រំឥស្លាមកម្ពុជាកាន់តែមានវឌ្ឍនភាព ឆ្លើយតបទៅនឹងបរិការណ៍ថ្មីៗ នៃសង្គម-សេដ្ឋកិច្ច ទាំងក្នុងតំបន់ និងពិភពលោក និងជាពិសេសក្នុងខណៈដែលកម្ពុជាកំពុងរក្សាបាន នូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ ព្រមទាំងធានាបាននូវភាពសុខដុម និងប្រក្រតីភាពនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ ជាការពិត វឌ្ឍនភាពនៃវិស័យអប់រំឥស្លាមនេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ គឺបានស្តែងចេញពីកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហការយ៉ាងជិតស្និទ្ធរបស់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ គ្រូបង្រៀន មាតាបិតា សិស្ស និស្សិត សហគមន៍ និងភាគីពាក់ព័ន្ធទូទាំងប្រទេស ដែលតែងតែយកចិត្តទុកដាក់រួម

ចំណែកអភិវឌ្ឍវិស័យអប់រំ និងការកសាងធនធានមនុស្សប្រកបដោយស្មារតីទទួលខុសត្រូវ តាមតួនាទី និងភារកិច្ចរៀងៗខ្លួន។

ទន្ទឹមនេះ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ ចំពោះគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា សមាគមគ្រូបង្រៀនខ្មែរឥស្លាម ដៃគូអភិវឌ្ឍជាតិ-អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានសហការ និងផ្តល់ការឧបត្ថម្ភគាំទ្រទាំងសម្ភារៈ ថវិកា បច្ចេកទេស លើការជួយរៀបចំផែនការសកម្មភាព និងការជួយជ្រោមជ្រែងក្នុងការអនុវត្តន៍សកម្មភាពការងារក្នុងវិស័យអប់រំឥស្លាមនាពេលកន្លងមក។

ជាមួយគ្នានេះ គួរកត់សម្គាល់ថា វឌ្ឍនភាពនៃវិស័យអប់រំឥស្លាមនេះ ពិតជាបានរួមចំណែកយ៉ាងសំខាន់ដល់ការរីកលូតលាស់ នៃសង្គម និងសេដ្ឋកិច្ចកម្ពុជា។ ក្នុងនោះ កម្ពុជាត្រូវបានទទួលស្គាល់ជាប្រទេស ដែលមានការអភិវឌ្ឍន៍ឆាប់រហ័ស ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទាំងផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសេវាកម្ម និងជាប្រទេសគំរូដ៏ល្អ ដែលរក្សាបាននូវសុខសន្តិភាព ស្ថេរភាពនយោបាយ និងសុខដុមបនីយកម្មសាសនា។ កម្ពុជាកំពុងស្ថិតលើផ្លូវដ៏ត្រឹមត្រូវ លើការងារអភិវឌ្ឍ ដែលធ្វើឱ្យកម្ពុជាកាន់តែរីកចម្រើនឡើងជាលំដាប់លើគ្រប់វិស័យពីមួយឆ្នាំទៅមួយឆ្នាំ ជាក់ស្តែង កម្ពុជាបានអភិវឌ្ឍខ្លួន តាំងពីមានអ្នកចេះដឹងក្នុងចំនួនតិចតួចបំផុត នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ដែលជាដំណាកាលអនុវត្តកម្មវិធី "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ" រហូតឈានដល់បង្កើតបានជាប្រព័ន្ធ ដែលមានស្តង់ដារនៅគ្រប់កម្រិត នៃការអប់រំបណ្តុះបណ្តាល។ ការណ៍នេះ សបញ្ជាក់ឱ្យឃើញថា វិស័យអប់រំពិតជាមានការវិវឌ្ឍគួរឱ្យកត់សម្គាល់ ដែលនេះ គឺជាប្រវត្តិសាស្ត្រ នៃការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា។

គួររំលឹកផងដែរថា ជាទំព័រប្រវត្តិសាស្ត្រថ្មីមួយសម្រាប់សហគមន៍ឥស្លាម នៅឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន **អតីតនាយករដ្ឋមន្ត្រី** ដោយមើលឃើញពីការលំបាក និងតម្រូវការចាំបាច់របស់សហគមន៍ឥស្លាមកម្ពុជា **សម្តេចតេជោ** បានបានសម្រេចផ្តល់ជូនដល់សហគមន៍ឥស្លាមនូវគ្រូបង្រៀនខ្មែរឥស្លាមចំនួន ១,៥០០នាក់ ចូលក្របខណ្ឌរដ្ឋ នៃក្រសួងអប់រំ យុវជន និងកីឡា។

**អ្នកឧកញ៉ាចាងហ្វាង ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គមហាសន្និបាតទាំងមូលជាទីមេត្រី!**

ការអប់រំកម្រិតចំណេះទូទៅ និងការអប់រំផ្នែកសាសនាពិតជាមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ការអប់រំផ្នែកសាសនារួមចំណែកជួយពង្រឹងសិស្សានុសិស្ស ឱ្យមានការទទួលខុសត្រូវ មានសីលធម៌ និងអាកប្បកិរិយាថ្លៃថ្នូរ ដើម្បីក្លាយខ្លួនជាពលរដ្ឋល្អ មានមហិច្ឆតាក្នុងការសិក្សា ផ្តល់នូវចំណេះដឹងទូទៅយ៉ាងទូលំទូលាយ និងការអភិវឌ្ឍន៍វិជ្ជាជីវៈក្នុងវិស័យផ្សេងៗជាច្រើនទៀត ដែលជាមូលដ្ឋានដ៏សំខាន់បំផុត សម្រាប់ឈោងទៅចាប់យកការបណ្តុះបណ្តាលនៅក្នុងកម្រិតខ្ពស់តទៅទៀត។ កិច្ចការទាំងអស់នេះ គឺជាគន្លឹះ ដើម្បីសម្រេច

បាននូវយុទ្ធសាស្ត្រលើកស្ទួយសមត្ថភាព កម្រិតជំនាញយុវជនកម្ពុជាឱ្យឆ្លើយតបទៅនឹងនិន្នាការវិវឌ្ឍន៍ នៃវិស័យបច្ចេកវិទ្យា និងជួយសិស្សនិស្សិតឱ្យទទួលបានជោគជ័យនៅក្នុងជីវិត។

តាមរយៈនេះ ខ្ញុំសូមគាំទ្រចំពោះអនុសាសន៍ និងវិធីសាស្ត្រថ្មីៗ ដូចមានក្នុងរបាយការណ៍បូកសរុបលទ្ធផលមហាសន្និបាតរបស់ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានសមាគមគ្រូបង្រៀនខ្មែរឥស្លាម ដែលបានបង្ហាញពីសមិទ្ធផល និងទិសដៅដែលត្រូវបន្តអនុវត្ត ក្នុងគោលដៅបង្កើនសមត្ថភាព និងជានាគុណភាពវិស័យអប់រំឥស្លាមនៅកម្ពុជា ។ ក្នុងនោះក្រសួងអប់រំ យុវជន និងកីឡានឹងបន្តគិតគូរយកចិត្តទុកដាក់បន្ថែម ក្នុងរួមចំណែកអភិវឌ្ឍវិស័យអប់រំឥស្លាម តាមរយៈការបណ្តុះបណ្តាលគ្រូបង្រៀនជាអាទិភាពចម្បង ដើម្បីគាំទ្រការធ្វើវិក្រឹតការគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា គាំទ្រការងារអធិការកិច្ច ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងគុណភាពសិក្សា និងគុណភាពប្រឡងជាដើម។ ទន្ទឹមនេះ ក្រសួងនឹងបន្តគិតគូរអំពីការអភិវឌ្ឍគុណវឌ្ឍគ្រូបង្រៀន និងបុគ្គលិកសិក្សាក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យមានលក្ខណៈសមស្របតាមស្តង់ដាគ្រូបង្រៀនចំណេះទូទៅ ។

ខ្ញុំសូមគាំទ្រនូវទស្សនទានក្នុងការប្រែក្លាយគ្រឹះស្ថានសិក្សាសហគមន៍ទៅជាគ្រឹះស្ថានសិក្សាសាធារណៈ ដោយក្រសួងនឹងពិចារណាពិនិត្យអំពីលទ្ធភាពក្នុងការដាក់បញ្ចូលគ្រឹះស្ថានសិក្សាឥស្លាមមួយចំនួន ជាគ្រឹះស្ថានសាធារណៈ ដោយស្នើរៀបចំសំណុំបែបបទត្រឹមត្រូវដាក់ជូនក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យសម្រេចចេញប្រកាសទទួលស្គាល់ជាផ្លូវការ។ ជាមួយគ្នានេះក្រសួងអប់រំ យុវជន និងកីឡា បានគិតគូរពីលទ្ធភាពកំណែទម្រង់គ្រឹះស្ថានសិក្សា តាមរយៈការរៀបចំឱ្យមានជាគ្រឹះស្ថានសិក្សាស្តង់ដា (គ្រឹះស្ថានសិក្សាគំរូ) ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ ដោយធ្វើការវាយតម្លៃ និងជ្រើសរើសគ្រឹះស្ថានសិក្សានៅតាមសហគមន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទាំងហេដ្ឋារចនាសម្ព័ន្ធ ផ្នែករឹង និងផ្នែកទន់។

ជាមួយនេះ យើងក៏ត្រូវយកចិត្តទុកដាក់គាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា ឧស្សាហកម្ម ការបំពាក់ជំនាញឌីជីថល ដូចជាស្តែមជាដើម ចាប់ពីនៅគ្រប់កម្រិតសិក្សា ព្រមទាំងគាំទ្រការផ្តល់អាហារូបករណ៍ និងបង្កលក្ខណៈងាយស្រួលដល់យុវជនផ្ទើម ឱ្យទទួលបានការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមគ្រប់រូបភាព ទាំងសាលារៀនរដ្ឋ សហគមន៍ និងឯកជន។ ជាងនេះទៅទៀត យើងត្រូវបន្តចូលរួមយកចិត្តទុកដាក់ជាមួយរាជរដ្ឋាភិបាលលើការពង្រីកចំនួនសាលារៀននៅគ្រប់កម្រិត និងការសាងសង់អគារសិក្សាថ្មី ព្រមទាំងជួសជុលអគារសិក្សាទ្រុឌទ្រោម សាងសង់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បណ្ណាល័យ និងបន្ទប់កុំព្យូទ័រជាដើម។

ព្រមជាមួយនេះ ក្នុងស្មារតីបន្តលើកស្ទួយ និងអភិវឌ្ឍន៍វិស័យអប់រំកម្ពុជា ជាពិសេសវិស័យអប់រំឥស្លាម ឱ្យឈានទៅសម្រេចបានតាមគោលដៅនៃគោលនយោបាយអភិវឌ្ឍវិស័យអប់រំ រយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយត្រូវបន្តយកចិត្តទុកដាក់ខ្ពស់លើការងារសំខាន់ៗ ដូចជា ៖

- កាអនុវត្តកំណែទម្រង់នៅគ្រប់កម្រិតសិក្សា ដោយមានកំណត់សូចនាករ និងសមិទ្ធកម្មច្បាស់លាស់
- ការពង្រឹងអភិបាលកិច្ច និងពង្រឹងរចនាសម្ព័ន្ធដឹកនាំ
- ការលើកកម្ពស់គុណវុឌ្ឍគ្រូ

- ការកែលម្អ និងរៀបចំកម្មវិធីសិក្សាស្តង់ដាររួម
- ការកែលម្អធនធានសិក្សា និងសៀវភៅសិក្សាគោល
- ការប្រើប្រាស់បច្ចេកវិទ្យា
- ការអនុវត្តវិធីសាស្ត្របង្រៀនបែបទំនើប
- ការរួមបញ្ចូលកម្មវិធីស្រាវជ្រាវដោយផ្តោតលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និង
- ការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជាដើម។

ក្នុងអត្ថន័យដូចបានលើកឡើងមកនេះ ខ្ញុំជឿជាក់ថា អង្គមហាសន្និបាតនឹងយកធ្វើជាមូលដ្ឋានពិចារណា និងរៀបចំជាធាតុចូលបន្ថែម សម្រាប់អនុវត្តក្នុងទិសដៅឆ្នាំសិក្សាថ្មីនេះ និងឆ្នាំបន្តបន្ទាប់ទៀត ឱ្យកាន់តែទទួលបានលទ្ធផលល្អប្រសើរ ខណៈដែលការអប់រំនេះ គឺជាកិច្ចការអាទិភាពរបស់ជាតិ ដែលត្រូវធ្វើជាប្រចាំ និងត្រូវបន្តធ្វើមិនឈប់ឈរពីជំនាន់មួយទៅជំនាន់មួយទៀត។

**អ្នកឧកញ៉ាចាងហ្វាង ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គមហាសន្និបាតទាំងមូលជាទីមេត្រី!**

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណម្តងទៀត ចំពោះ ថ្នាក់ដឹកនាំគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ថ្នាក់ដឹកក្រសួងស្ថាប័នពាក់ព័ន្ធ បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ព្រមទាំង អាជ្ញាធរមូលដ្ឋាន វិស័យឯកជន សប្បុរសជន និងសហគមន៍ទាំងអស់ ដែលបានសហការ និងចូលរួមគាំទ្រយ៉ាងសកម្មដល់ការអភិវឌ្ឍវិស័យអប់រំឥស្លាមនៅកម្ពុជា ប្រកបដោយជោគជ័យ ក្នុង ឆ្នាំសិក្សាកន្លងទៅ និងសូមលើកទឹកចិត្តឱ្យមានការបន្តផ្តល់នូវការឧបត្ថម្ភគាំទ្រ និងបន្តចូលរួម ដើម្បីជាឧត្តមប្រយោជន៍ដល់កុមារ និង យុវជនកម្ពុជាគ្រប់រូប ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ **អ្នកឧកញ៉ា ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ និង អង្គមហាសន្និបាតទាំងមូល** សូមប្រកបដោយសេចក្តីសុខ សេចក្តីចម្រើន និងទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ។

ក្នុងនាម **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ខ្ញុំសូមប្រកាសបិទ **មហាសន្និបាតបូកសរុបការងារអប់រំឥស្លាម ឆ្នាំ២០១៥-២០២៣ និងលើកទិសដៅការងារបន្ត** ចាប់ពីពេលនេះ តទៅ ។

*សូមអរគុណ!*

# ឧបសម្ព័ន្ធទី៣ កម្រងរូបភាពសកម្មភាពក្នុងមហាសន្និបាត

## កម្រងរូបភាព

## មហាសន្និបាតបូកសរុបការងារអប់រំឥស្លាម ឆ្នាំ២០១៥-២០២៣ និងទិសដៅការងារបន្ត

## ក្រោមប្រធានបទ៖ «កំណែទម្រង់វិស័យអប់រំឥស្លាមក្នុងបរិបទឌីជីថល»

*ពិធីបើកមហាសន្និបាត*





*គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា*






*ការសូត្រគម្ពីរអាល់គួរអានុលការីម ដោយ **លោក នី អះម៉ាត់***





*របាយការណ៍ស្វាគមន៍ ដោយ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការបច្ចេកទេសមហាសន្និបាត*















*សុន្ទរកថាបើកមហាសន្និបាតដោយ **ឯកឧត្តមបណ្ឌិត អូស្មាន ហាស្សាន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស*





*បាឋកថាពិសេសស្តីពីៈ **វឌ្ឍនភាពនៃវិស័យអប់រំឥស្លាមកម្ពុជា** ដោយ **អ្នកឧកញ៉ា សុះ កំរី***
*ចាងហ្វាងគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា*





*បទអន្តរាគមន៍ស្តីពីៈ **បទពិសោធន៍ការធ្វើកំណែទម្រង់វិស័យអប់រំនៅកម្ពុជា** ដោយ **លោក កែវ សារ៉ាត់***

## វេទិកាពិភាក្សាទី១៖ **ស្តីពីស្ថានភាពអប់រំឥស្លាម**














*ការចូលរួមសួរសំណួរ និងលើកឡើងនូវមតិយោបល់ របស់អង្គមហាសន្និបាត ក្នុងវេទិកាពិភាក្សាទី១*

## វេទិកាពិភាក្សាទី២៖ **ស្តីពីទិសដៅការងារអប់រំឥស្លាម**











បទបង្ហាញស្តីពីបទពិសោធន៍នៃការគ្រប់គ្រងសាលាបឋមសិក្សាវត្តបូ ដោយ **ឯកឧត្តម ពឹង គិមឆេន**





បទបង្ហាញស្តីពីការចូលរួមរបស់សហគមន៍គាំទ្រសាលារៀន ដោយ **លោក ទូលាស់ សាប់អះ**




*ការចូលរួមសួរសំណួរ និងលើកឡើងនូវមតិយោបល់ របស់អង្គមហាសន្និបាត ក្នុងវេទិកាពិភាក្សាទី២*







*មតិបូកសរុបអង្គពិភាក្សាមហាសន្និបាត ដោយ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការបច្ចេកទេស*



*ការប្រកាសលទ្ធផលជ័យលាភីការតែងនិពន្ធខុទ្ទពះ ដោយ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការបច្ចេកទេស*



## *ពិធីបិទមហាសន្និបាត*











*របាយការណ៍បូកសរុបមហាសន្និបាតដោយ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការបច្ចេកទេសមហាសន្និបាត*










*សុន្ទរកថាថ្លែងក្នុងពិធីបិទមហាសន្និបាតដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុន រឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងអប់រំ យុវជន និងកីឡា*



*ការប្រគល់លិខិតសរសើរជូនតំណាងវាគ្មិន*



*ការប្រគល់លិខិតសរសើរជូនតំណាងគណៈកម្មការ*



*ជ័យលាភីលេខ១ ផ្នែកតែងនិពន្ធខុទ្ទពះ*



*ការប្រគល់លិខិតថ្លែងអំណរគុណតំណាងដៃគូសហការឧបត្ថម្ភ*

## គណៈអធិបតីអញ្ជើញទស្សនាស្តង់តាំងពិព័រណ៌
## ដាក់បង្ហាញអំពីសមិទ្ធផលអប់រំរបស់គ្រឹះស្ថានសិក្សាសហគមន៍ និងអង្គការ សមាគម
















Welcome






អរគុណសន្តិភាព



## ឧបសម្ព័ន្ធទី៤ បញ្ជីឈ្មោះអ្នកចូលរួមមហាសន្និបាតអប់រំផ្លូវ

តារាងសមាសភាពចូលរួម
មហាសន្និបាតបូកសរុប កាងារវិស័យអប់រំផ្លូវ ឆ្នាំ២០២៥-២០១៣ និងលើកទិសដៅបន្ត
កាលបរិច្ឆេទៈ ថ្ងៃទី ០៥-០៦ ខែមិនា ឆ្នាំ២០២៣

| ល.រ | ស្ថាប័ន ឬអង្គភាព/រាជធានីខេត្ត/តួនាទី | តំណាងស្ថាប័ន អង្គភាព អង្គការ និងក្រុមហ៊ុន | | | សរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | វាគ្មិន | អ្នកសម្របសម្រួល | អ្នកចូលរួម | | |
| 1 | តំណាងឧបនាយករដ្ឋមន្ត្រី | 0 | 0 | 1 | 1 | |
| 2 | ទេសរដ្ឋមន្ត្រី | 0 | 0 | 1 | 1 | |
| 3 | អ្នកចាងហ្វាង | 0 | 0 | 1 | 1 | |
| 4 | សមាជិកព្រឹទ្ធសភា | 0 | 0 | 1 | 1 | |
| 5 | សមាជិករដ្ឋសភា | 0 | 0 | 3 | 3 | |
| 6 | រដ្ឋលេខាធិការ | 0 | 0 | 16 | 16 | |
| 7 | អនុរដ្ឋលេខាធិការ | 0 | 0 | 25 | 25 | |
| 8 | ទីប្រឹក្សាជាន់ខ្ពស់នៃរដ្ឋសភា | 0 | 0 | 1 | 1 | |
| 9 | ទីប្រក្សាព្រឹទ្ធសភា | 0 | 0 | 1 | 1 | |
| 10 | ទីប្រឹក្សាសម្ដេចសាយឈុំ | 0 | 0 | 1 | 1 | |
| 11 | ទីប្រឹក្សាក្រសួងព័ត៌មាន | 0 | 0 | 1 | 1 | |
| 12 | ទីប្រក្សារាជរដ្ឋាភិបាល | 0 | 0 | 18 | 18 | |
| 13 | ទីប្រឹក្សាក្រសួងធម្មការ និងសាសនា | 0 | 0 | 1 | 1 | |
| 14 | ទីប្រឹក្សារដ្ឋសភា | 0 | 0 | 1 | 1 | |
| 15 | ក្រសួងអប់រំយុវជន និងកីឡា | 0 | 0 | 10 | 10 | |
| 16 | ឯកអគ្គរាជទូត | 0 | 0 | 5 | 5 | |
| 17 | វាគ្មិន | 8 | 0 | 0 | 8 | |
| 18 | គណកម្មការខុតពះ | 0 | 0 | 10 | 10 | |
| 19 | បេក្ខភាពខុតពះ | 0 | 0 | 17 | 17 | |

| | | | | | | |
|---|---|---|---|---|---|---|
| 20 | ក្រុមប្រឹក្សាខេត្ត | 0 | 0 | 5 | 5 | |
| 21 | អភិបាលរងខេត្ត | 0 | 0 | 6 | 6 | |
| 22 | អភិបាលរងក្រុង | 0 | 0 | 6 | 6 | |
| 23 | អភិបាលរងស្រុក | 0 | 0 | 35 | 35 | |
| 24 | អភិបាលរងខណ្ឌ | 0 | 0 | 1 | 1 | |
| 25 | សមាគមអង្គការក្រៅការងារអប់រំ | 0 | 0 | 13 | 13 | |
| 26 | ក្រុមហ៊ុន | 0 | 0 | 11 | 11 | |
| 27 | ក្រុមការងារ | 0 | 25 | 0 | 25 | |
| 28 | យុវជនស្ម័គ្រចិត្ត | 0 | 15 | 0 | 15 | |
| 29 | គណៈដឹកនាំ | 0 | 17 | 0 | 17 | |
| 30 | ក្រុមការងាររូបភាព | 0 | 38 | 0 | 38 | |
| 31 | សមាគមអង្គការការងារអប់រំ | 0 | 0 | 44 | 44 | |
| 32 | ស្តង់ពិពរណ៍ | 0 | 0 | 59 | 59 | |
| 33 | នាយកសាលាស្តង់ពិពរណ៍ | 0 | 0 | 4 | 4 | |
| 34 | មន្ទីរអប់រំយុវជននិងកីឡា | 0 | 0 | 21 | 21 | |
| 35 | ការិយាល័យអប់រំស្រុកខណ្ឌ | 0 | 0 | 20 | 20 | |
| 36 | បន្ទាយមានជ័យ | 0 | 0 | 3 | 3 | |
| 37 | បាត់ដំបង | 0 | 0 | 8 | 8 | |
| 38 | កំពង់ចាម | 0 | 0 | 10 | 10 | |
| 39 | កំពង់ឆ្នាំង | 0 | 0 | 15 | 15 | |
| 40 | កំពង់ស្ពឺ | 0 | 0 | 2 | 2 | |
| 41 | កំពង់ធំ | 0 | 0 | 6 | 6 | |
| 42 | កំពត | 0 | 0 | 6 | 6 | |
| 43 | កណ្តាល | 0 | 0 | 14 | 14 | |
| 44 | កោះកុង | 0 | 0 | 5 | 5 | |
| 45 | ក្រចេះ | 0 | 0 | 11 | 11 | |
| 46 | មណ្ឌលគីរី | 0 | 0 | 5 | 5 | |
| 47 | រាជធានីភ្នំពេញ | 0 | 0 | 27 | 27 | |
| 48 | ព្រៃវែង | 0 | 0 | 3 | 3 | |

| | | | | | | |
|---|---|---|---|---|---|---|
| 49 | ពោធិ៍សាត់ | 0 | 0 | 9 | 9 | |
| 50 | រតនគីរី | 0 | 0 | 4 | 4 | |
| 51 | សៀមរាប | 0 | 0 | 3 | 3 | |
| 52 | ព្រះសីហនុ | 0 | 0 | 2 | 2 | |
| 53 | ស្ទឹងត្រែង | 0 | 0 | 14 | 14 | |
| 54 | តាកែវ | 0 | 0 | 3 | 3 | |
| 55 | ប៉ៃលិន | 0 | 0 | 1 | 1 | |
| 56 | កែប | 0 | 0 | 2 | 2 | |
| 57 | ឧត្តរមានជ័យ | 0 | 0 | 1 | 1 | |
| 58 | ត្បូងឃ្មុំ | 0 | 0 | 63 | 63 | |
| 59 | សន្តិសុខ 4នាក់ និងសុខាភិបាល3 នាក់ | 0 | 0 | 7 | 7 | |
| | **សរុបរួម** | 8 | 95 | 563 | 666 | |